Tassaneavadey - Mittsalabaley - R. 4 26-5-54-
(53.4
1er Mai
INDOCHINE FRANCAISE RÉGIE DU DÉPÔT LÉGAL

ឆ្នាំទី ៤ លេខ ៣
ថ្ងៃទី ១ ខែមីនា

# ទស្សនាវដ្តី មិត្តសាលាបាលី

ផ្សាយចេញ

សាសនា, អក្សរសាស្ត្រ, ប្រវត្តិសាស្ត្រ

ចេញរាល់ខែ ទី១ នៃ ព.ស. ២៤៩៦
ប្រក្រតិទិនសុរិយគតិ គ.ស. ១៩៥៤



ទីចាត់ការនៅវត្តលង្កា
សង្កាត់លេខ ៦ ក្រុងភ្នំពេញ

មិត្តដែលបានអានទស្សនាវដ្តីនេះចាត់ទុកជាបានជួយលើកដំកើង
សាសនា អក្សរសាស្ត្រ នឹង ព្រះមហាក្សត្រ របស់ខ្លួន

បណ្ណាគារ ហួត-ហៀម

រោងពុម្ព ៣ភ លេខ ០១១ វិថីព្រែនគរភ្នំពេញ

# មាតិការឿង


| | | | |
|---|---|---|---|
| បណ្ណាធិការ | ហួត-ហៀម | ..........វិចារណកថា | ទំព័រ ១ |
| ព្រះទេពសត្ថា | គឹម-ត្ង | ..........អបាយមុខគឺអ្វី? | " ៣ |
| មហា | សម-ម៉ង | ..........ពត៌មានគួរជឿខ្លះ គួរគិតខ្លះ | " ៦ |
| លោក | អ៊ុត-ជង់ | ..........បុណ្យមាឃបូជា | " ៨ |
| ព្រះញាណកោសល | ញាណ-ឈឹង | ..........ការប្រឡងបេក្ខសមណៈដែនកូសាំងស៊ីន | " ១០ |
| លោក | ចាប-ពិន | ..........ទំនៀមទម្លាប់នឹងឧត្តមប្រយោជន៍ | " ១២ |
| មហា | ប. ស. | ..........ដំណើរសម្តេចព្រះមហាសុមេធាធិបតី | " ១៥ |
| បណ្ណាធិការ | ហួត-ហៀម | ..........បុណ្យព្រហ្មទាន | " ១៦ |
| លោក | អ៊ុត-ជង់ | ..........ប្រវត្តិសាស្ត្រប្រទេសកម្ពុជាសង្ខេប | " ១៨ |
| " | ហោង-យ៉ាង | ..........ទំនប់ ១០ បាទ | " ២១ |
| " | ញូង-សៀង | ..........រឿងតាជ្រា | " ២៣ |
| មហា | ឆាន់ | ..........ជាតិមានអ្វីជាកំឡាំង | " ២៥ |
| លោក | ហ៊ុយ-ប៊ុក | ..........វិធានសុរិយគតិ | " ២៨ |
| " | តែ-ផុង | ..........រឿងជ័យប្រាជ្ញ | " ៣០ |
| " | ហ៊ុយ-ប៊ុក | ..........ទៅស្ថានទន្សាយធ្វើដំណើរតាំងពីភពលោក | " ៣១ |
| ព្រះមហា | ចាន់-ខាត់ | ..........បញ្ចតន្ត្រៈ | " ៣២ |
| បណ្ណាធិការ | ហួត-ហៀម | ..........ប្រវត្តិនៃក្មេងកំព្រា | " ៣៣ |


## ថ្លៃជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ខែ ៤៥៛០០ | ១ ឆ្នាំ ៩០៛០០ | ១ ក្បាល ៩៛០០ | ៦ខែ ៥៥៛០០ | ១ឆ្នាំ ១០៥៛០០ | ១ក្បាល ១០៛០០ |

B-K-27
1954-3





# ពុទ្ធចក្រ សាសនចក្រ អាណាចក្រ

សូមអស់លោកអ្នកអានទាំងឡាយ កុំភាន់ច្រឡំ ចំពោះគោលទាំងបីនេះ ៗ ខ្ញុំសូមលើកយកគោលទាំងបីនេះមកពណ៌នាជាសេចក្ដីខ្លីជូនអស់លោកអ្នក ៗ

ពុទ្ធចក្រ យើងនឹងរាប់បានថា សម័យពីព្រះសមណគោតមបរមសម្ពុទ្ធ បានសម្រេចព្រមទូវព្រះញាណដ៏បរិសុទ្ធក្រោមពោធិមណ្ឌល នាកាលថ្ងៃមួយពេញខែពិសាខ ដែលលោកសាចផ្សាយព្រះនាមបានជាព្រះពុទ្ធពិត ៗ សូមកុំភាន់ច្រឡំ មុនពេលដែលព្រះសិទ្ធត្ថគោតម បានឡើងឋានៈជាព្រះពុទ្ធគឺ ថ្ងៃ ១៥កើតខែវិសាខៈ ពេលនោះយើងគួរចាត់ទុកជា ទុក្ករ-កិរិយដែលព្រះអង្គកំពុងតែដំហានទៅកាន់ឋានៈ ដែលពិភពលោកតែងចង់ឃើញមកយូរហើយ គឺដំហានជាទីបំផុត ក្រៅពីដំហាន ដែលទ្រង់សាងមកជាច្រើនអសង្ខេយ្យកប្បមកនោះ យើងមិនអាចពណ៌នាបានទេ អំពីការស្មុគស្មាញសម្រាប់កាំងដំណើរព្រះអង្គ ៗ យើងសូមបញ្ជាក់ថា ព្រោះបីព្រះអង្គជិតផុតកន្លងនៃព្រះដំណើរក៏ដោយ ក៏គង់នៅមានហេតុអស្ចារ្យ ដែលបង្អមកប្រហារព្រះជន្ម ព្រះអង្គដែរ ដូចផ្សាយស្រាប់ហើយថា: ពេលនោះមារទេវបុត្រលើកទ័ពមកច្រើនជាអនេក លុះត្រាតែទេវបុត្រទេវតាទាំងឡាយកំពុងតែបោមពេមរត់បោលព្រះអង្គអស់ដោយខ្លាចឫទ្ធិរបស់មារាធិរាជ ដែលជាអ្នកមានបំណងចំពោះបល្ល័ង្ករតន៍ ៗ តែព្រះសិទ្ធត្ថគោតមបរមពោធិសត្វ ទ្រង់គ្មានសេចក្ដីតក់ស្លុតអ្វីកង់ព្រះអង្គឡើយ គង់កន្ដើយដូចជាស្ដេចចក្រនាកណ្ដាលរាជសេវកាមាត្យ ទ្រង់ប្រថាប់ដោយគុណ្ហីភាព ៗ តើពេលនោះព្រះអង្គបានឈ្នះមារដោយប្រការដូចម្ដេច? សូមកុំធ្ងល់ចំពោះរឿងនេះ ការដែលឈ្នះនោះមានហេតុដូចតទៅ ៗ មារចិត្តបាប បានមកក្ដែងបោចចំពោះព្រះអង្គដោយកំហុសដូច្នេះ:

ឱ! សិទ្ធត្ថ ម្ដេចក៏អ្នកមកធ្វើជាចោរ អួតថាអ្នកមកបំពេញញាណដើម្បីជាព្រះពុទ្ធ ចុះពេលនេះ, រតនៈបល្ល័ង្ករបស់យើង ដែលមានសេនាទាំងសែនជាអ្នកដឹងឮ ថារតនៈបល្ល័ង្ក ផុសសម្រាប់បារមីរបស់យើង, ម្ដេចក៏អ្នកអង្គុយធ្វើរាហ៊ីដូចជារបស់អ្នកឯង យើ! សិទ្ធត្ថ យើងនឹងចាប់អ្នកគ្រវាត់ផុតកណ្ដាប់ចក្រវាឡឥឡូវនេះ បើអ្នកនៅតែរឹងអង្គុយមិនចុះ ៗ

ចុះពេលនោះព្រះអង្គទ្រង់ធ្វើសង្គ្រាមតបមារាធិរាជ ដោយប្រការដូចម្ដេច?

ពេលនោះទ្រង់យកអាវុធវិសេសមួយ ឈ្មោះថា សច្ចធម៌ មកធ្វើសង្គ្រាមផ្ចាញ់មារ ដោយទ្រង់មាន

ព្រះបន្ទូលដ៏ស្រទន់តបទៅកាន់មារវិញថា អើមារ! អ្នកអាងថា រតនៈបល្ល័ង្កផុសសម្រាប់អ្នក តើអ្នកមានអ្វីជាបន្ទាល់?

មារក៏បង្អុលទៅសេនាទាំងឡាយរបស់ខ្លួនថា នេះហើយជាបន្ទាល់របស់យើង ពួកពលមារក៏ស្រែកព្រមគ្នាថាបល្ល័ង្ករតន៍ផុសឡើង សម្រាប់ម្ចាស់របស់យើង ៗ មារបានឱកាស ពោលបញ្ជាក់ថា ហ៊ឺ! សិទ្ធត្ថ អ្នកឮទេ គេឆ្លើយព្រមគ្នា, ចុះអ្នកឯងបានអ្វី? ព្រះសិទ្ធត្ថគោតមបរមពោធិសត្វ ទ្រង់យកព្រះហស្ត បង្អុលទៅកាន់ផែនដីហើយមានព្រះបន្ទូលថា នេះហើយជាបន្ទាល់របស់យើង ៗ មហាប្រឹថពីដែលមានកម្រាស់ដ៏ក្រាស់ ជាធម្មជាតិគ្មានវិញ្ញាណ ពេលនោះសព្ទដ៏ខ្ទររំពងបាន បញ្ចេញពីស្រទាប់នៃផែនដីឲ្យឮច្បាស់ថា បល្ល័ង្ករតន៍នេះ ផុសសម្រាប់ព្រះសមណ-គោតមបរមពោធិសត្វ ដើម្បីការត្រាស់ដឹងរបស់ព្រះអង្គ (មិនមែនជាបល្ល័ង្កសម្រាប់មារឯងទេ) នេះហើយជាសង្គ្រាមទីបំផុត ដែលព្រះអង្គទ្រង់បញ្ចប់នៅក្រោមពោធិមណ្ឌល, ដោយកម្លាំងសច្ចវាចានេះហើយ ដែលមារសេនារត់គ្មានសល់ ចំណែកមារាធិរាជ ក៏ថ្វាយបង្គំសូមចុះចាញ់ក្នុងពេលនោះ ៗ

សេចក្ដីនេះ ខ្ញុំគ្រាន់តែនាំមកជាគោលបង្ហាញថា កុំអាលរាប់ពីត្រឹមកាលនោះថា សម័យពុទ្ធចក្រ គឺត្រូវរាប់ពីត្រឹមថ្ងៃ ១ កើត ខែពិសាខវិញ ៗ

ព្រះសិទ្ធត្ថកាលបាននាមប្រាកដជាព្រះពុទ្ធហើយ ព្រះអង្គមិនដែលលះបោលនូវបំណងរបស់ព្រះអង្គឡើយ ព្រោះការកសាងជាព្រះពុទ្ធ ដោយទ្រង់មានព្រះបំណងស្រោចស្រង់សត្វនិករតែម្យ៉ាង ទោះបីជួបគ្រោះក៏ដោយ ក៏ព្រះអង្គទ្រង់គង់ដោយស្ងប់ស្ងៀមសិនដែរលុះតែព្រះព្រហ្មចុះមកអារាធនាព្រះអង្គ ទើបទ្រង់បំពេញតាមព្រះបំណងតទៅ ៗ សេចក្ដីនេះខ្ញុំសូមប្រៀបជូនឲ្យងាយស្ដាប់ថា ក្នុងរដ្ឋមួយប្រជារាស្ត្រទើបតែរៀបពិធីអភិសេកប្រមុខរដ្ឋមួយព្រះអង្គ ចំណែកព្រះរាជាអង្គថ្មីនោះ ព្រះអង្គទ្រង់មានអំណាចជាស្ដេចនឹងជាបសេចក្ដីវេទនារបស់ប្រជារាស្ត្រក៏ដោយ តែបើក្រុមជំនុំព្រះរាជវង្ស រដ្ឋមន្ត្រី រដ្ឋសភា ពុំទាន់ចូលខ្លួនទៅ ថ្វាយអំណាចចំពោះការគ្រប់គ្រងតាមកម្មវិធីណាមួយក៏ព្រះអង្គត្រូវតែគង់ជាសុខសិនដែរ ៗ សូមប្រាប់ដោយខ្លីថា ស្ដេចគ្រងរាជ្យពិតជាត្រូវទទួលអំណាចពីប្រជារាស្ត្ររបស់ព្រះអង្គ, ព្រះពុទ្ធបានត្រាស់ហើយពិតជាត្រូវមានព្រហ្មមកអារាធនា នេះជាការចាំបាច់ ៗ

យើងរាប់បានពីត្រឹមថ្ងៃដែលព្រះពុទ្ធបានត្រាស់ រហូតមកក្នុងរយៈពេលដែលទ្រង់គង់ប្រោសព្រះរាជ - ទានធម្មទេសនាដល់ប្រជាជនជាច្រើនក្នុងលោក អស់រយៈកាល ៤៥ ព្រះវស្សា ទាំងអស់នេះចាត់ទុកជាសម័យពុទ្ធចក្រគឺសម័យដែលព្រះអង្គ កំពុងសំដែងធម៌ចំពោះសត្វលោកដោយផ្ទាល់ព្រះឱស្ឋ ៗ

ចាប់រាប់តាំងពីព្រះអង្គចូលបរិនិព្វានទៅ សល់ព្រះអរហន្តជាច្រើនម៉ឺនអង្គ មានព្រះអរិយកស្សប

បាលីអានន្ទជាប្រធាននោះ លោកបានលើកពុទ្ធវចនៈ ទាំងឡាយមកចាត់ទុកជាពួកក្រុម ទល់គ្នានឹងសម័យនេះ ហៅថាសម័យសាសនចក្រ ឬពុទ្ធសាសនចក្រ ។ ដូចកាលជំនាន់ព្រះបាទធម្មាសោកមហារាជ ព្រះអង្គមានបន្ទូលទៅកាន់ភិក្ខុក្នុងសាសនាគ្រប់អង្គថា បពិត្រលោកម្ចាស់គ្រប់រូប អាណាចក្រទុកលើខ្ញុំព្រះករុណាជាអ្នកកាន់កាប់ផ្ទាល់ ចំណែកសាសនចក្រជាភារៈម្ចាស់លើលោកពលរូប ។ នេះសឲ្យឃើញថាឱកាសជាចន្លោះនេះឲ្យឈ្មោះថាសាសនចក្រ ។

ចំណែកអាណាចក្រមានជាប់ជានិច្ចក្នុងរដ្ឋមួយៗ ដែលជាច្បាប់ចេញពីប្រមុខរដ្ឋ សម្រាប់ប្រជាជនប្រតិបត្តិយកសុខក្នុងបច្ចុប្បន្ន មានការរក្សាសេចក្តីស្ងប់រៀបរយក្នុងប្រទេសជាដើម ។

សាសនចក្រនឹងអាណាចក្រនេះ មិនដែលឃ្លាតចាកគ្នាឡើយ ។ គួរប្រៀបឲ្យងាយស្តាប់ថា ទុកដូចជាស្វាមី ភរិយា ។ មនុស្សក្នុងលោកបើប្រាសចាកគូជាស្វាមីភរិយាហើយ ធ្វើម្តេចនឹងមានបុត្រជាដំណវង្សត្រកូល ។ អាណាចក្រ បើគ្មានសាសនានៅអែបជាជំហរធ្វើម្តេចនឹងញុំាងវឌ្ឍនាការឲ្យប្រព្រឹត្តទៅបាន ព្រោះអាណាចក្រតែងអប់រំទៅតាមអារ្យធម៌នៃសាស-នចក្រជានិច្ច ។ ដោយហេតុនោះហើយបានជាច្បាប់សម្រាប់រដ្ឋមួយៗ មានពោលពីសាសនាប្រចាំប្រទេស ដូចកម្ពុជរដ្ឋយើងនេះរដ្ឋធម្មនុញ្ញបានលើកព្រះពុទ្ធសា-សនាជាសាសនារបស់រដ្ឋថែមទាំងព្រះមហាក្សត្រជាអគ្គសាសនូបត្ថម្ភក៏ថែមទៀត ឃើញថាប្រទេសយើងគង់មានជំហរដ៏រឹងប៉ឹងដោយពិត, តែសូមអំពា-វនាវដល់វត្តុសក្តិសិទ្ធទាំងឡាយថា ជាការឧបត្ថម្ភព្រះពុទ្ធសាសនាសូមពឹងលើវជ្ជនគ្រប់រូបផង ទើបសេចក្តីចំរើននឹងផុះផុលដោយឆាប់រួសរាន់បាន ។ ចំ-ពោះជនរួមជាតិក៏សូមកុំមានត្រឹមតែហាចឲ្យសោះសូមប្រែកប់ទៅតាមទឹកចិត្តដ៏ស្មោះស្ម័គ្រផង ។

ជយោ ព្រះពុទ្ធសាសនាប្រទេសកម្ពុជា

ហួត-ហៀម

## អបាយមុខ គឺអ្វី?

គឺហេតុជាប្រធាននៃសេចក្តីវិនាសហិនហោច អាចឲ្យឃើញទាន់ភ្នែកក្នុងលោកនេះ ចំពោះអ្នកដែលបានប្រព្រឹត្ត ហៅថា អបាយមុខ ។ ធម្មតាមនុស្សក្នុងលោកសន្និវាសនេះ មិនថាជាន់ខ្ពស់ ជាន់កណ្តាលជាន់ទាបទេ ទោះមនុស្សប្រភេទណាក៏ដោយ គ្មានសេចក្តីស្អប់ខ្ពើមពុញទ្រាន់ ឬមិនត្រូវការនឹងសេចក្តីល្អ គឺសេចក្តីសុខនឹងសេចក្តីចំរើនគ្រប់ប្រការនោះទេ សុទ្ធសឹងតែជាអ្នកត្រូវការចង់បានដូចៗ គ្នាទាំងអស់ ប៉ុន្តែការចង់បាននោះ បែរជាផុតចាកសេចក្តីចំរើនខុសគោលបំណងរបស់ខ្លួនទៅវិញ ដោយការកាន់គំនិតយល់ខុសក៏មាន ដោយការសេពគប់ខុសក៏មាន សមដូចព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ចំពោះសិង្គាល

មាណពជាបុត្ររបស់គហបតីម្នាក់ថា ហេតុជាប្រធាន ដែលនាំឲ្យបុរសស្ត្រីអ្នកប្រព្រឹត្តបានទទួលនូវគ្រោះថ្នាក់អពមង្គលទាន់ហន់ក្នុងលោកនេះហៅថាអបាយមុខ មាន ៦ យ៉ាងគឺ:

អបាយមុខទី ១- ផុនដល់ការផឹកទឹកស្រវឹង គឺសុរាទឹកមេរ័យ ៗ ឯសុរាទឹកមេរ័យនេះ ជាទឹកសំរាប់បំពុលឬសំរាប់បង្វិលចិត្តមនុស្សឲ្យខុសប្រក្រតី, មនុស្សអ្នកត្រូវការក្រេបលេបទឹកស្រវឹងចូលទៅ, ទឹកនេះអាចកំដៅហទយៈគឺបេះដូងឲ្យញាប់ញ័រ ច្រើនតែបណ្ដាលឲ្យកើតសេចក្ដីក្លាហានព្រហើនគោងកាច ប្រមាថមើលងាយអ្នកដទៃ, អំពើខុសយល់ថាជាត្រូវ អំពើត្រូវយល់ថាជាខុសវិញ ៗ មនុស្សខ្លះ បើមិនទាន់ត្រូវសុរាចូលដល់ទេ, តែងមានឫកពាសុភាពរាបសាជឹងខុសត្រូវគួរសម, តែវេលាណាត្រូវសុរាហើយ, អំណាចសុរានេះ បង្វិលចិត្តឲ្យខុសប្រក្រតីមួយរំពេច គឺបញ្ចេញអាការថោកទាបដោយផ្លូវកាយនិងវាចា, ទៅជាមនុស្សប្រឆេងប្រឆាំងទ្រាក់ទ្រើកញញាក់ញញ័រ ចាំងសំដីសោតទៀត ក៏និយាយច្រំដែល ៗ មិនទៅមុខ ចេញលំនាំប្រហែលគ្នានឹងមនុស្សវិកលចរិត ៗ មនុស្សប្រមឹកញៀនសុរានេះ រមែងទទួលនូវទុក្ខទោសគ្រោះថ្នាក់ ៦ យ៉ាង អាចឲ្យឃើញជាក់ច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្នជាតិនេះគឺ:

១- អ្នកប្រមឹកសុរា តែងចាយវាយទ្រព្យសម្បត្តិកញ្ជះកញ្ជាយ, យកទៅទិញសុរាខ្លះ សាច់ខ្លះ ឬរបស់អ្វីឯទៀតខ្លះ សំរាប់ក្លែមជាមួយនឹងសុរា, អ្នកខ្លះថា ស៊ីផឹកម្នាក់ឯង មិនសូវឆ្ងាញ់ មិនសូវសប្បាយទេ, លុះតែមានគ្នាច្រើនហ៊ុហាសប្បាយ, ម្ល៉ោះហើយក៏ហៅគេប្រមូលមនុស្សណា ដែលមានចរិយាថោកទាបដូចខ្លួនដែរ មកស៊ីផឹកជាមួយ, អ្នកប្រមឹកសុរាបែបនេះ គ្មានពេលឱកាសនឹងធ្វើការស្វែងរកទ្រព្យសម្បត្តិទេ, មានតែផ្លូវចាយវាយបំផ្លិចបំផ្លាញតែម្យ៉ាង,កាលបើប្រាក់កាសសំរាប់ចាយធម្មតាមិនគ្រប់គ្រាន់ទេ, ក៏គោងលក់ឬបញ្ចាំគ្រឿងតិកមានផ្ទះសម្បែងដីស្រែចំការច្បារដំណាំជាដើម ដរាបទាល់តែអស់រលីង, ក៏តាំងសំកុកកើតទុក្ខមុខស្ងួត អស់ទាំងគ្រួសារថ្នាក់ខ្លួនទៅជាមនុស្សអនាថាឥតទីពឹងរហេមរហាម ក្លាយទៅជាចោរលួច ចោរប្លន់ក៏មាន ៗ

២- អ្នកប្រមឹកសុរា ពេលណាស្រវឹងស៊ប់ហើយ ក៏តាំងបង្កហេតុរករឿងឈ្លោះជេរប្រទេចប្រពន្ធកូនឯង, បើរករឿងប្រពន្ធកូនរបស់ខ្លួនមិនបានទេ, ក៏បែរទៅរករឿងឈ្លោះនឹងរបស់ប្រើប្រាស់មានពាង ចានទឹង-ឆ្នាំងជាដើម វាយសំពងបែកបាក់ខ្ទេចខ្ទីអស់ក៏មាន, បើមិនដូច្នោះទេ, បង្កហេតុរករឿងអ្នកជិតខាង គេអត់មិនបាន ក៏កើតទៅជាជេរតបវាយដំកាប់ចាក់គ្នាទៅវិញទៅមក ជាប់គុកច្រវាក់បង់ទ្រព្យធនធានថែមទៀតក៏មាន ៗ ៣- អ្នកប្រមឹកសុរា ឈ្មោះថាជាអ្នកបង្ករោគផ្សេងៗ ឲ្យកើតចំរើននៅក្នុងរាងកាយរបស់ខ្លួន, មានរោគថ្លើមក្អក ខូចក្រពះ ខូចពោះវៀន ខូចសួត

ជាដើម ឆាប់ចាស់ផុតអាយុខ្លីដោយអំណាចសុរាក៏មាន ។ ៤-អ្នកប្រមឹកសុរា មានកិត្តិសព្ទអាក្រក់ ឈ្មោះជាទីខ្ពើមរអើមរបស់ពួកសប្បុរស ទាំងសំដីនិយាយកិច្ចការអ្វីសោតទៀត, គេក៏មិនសូវជឿស្ដាប់មិនយកជាប្រមាណ, បើទុកជាមានកូនកំឡោះក្រមុំប្រុសស្រី, គេក៏មិនត្រូវការ ថែមទាំងគេជៀសវាងពួកប្រមឹកសុរាកុំចូលជិត, នាំឲ្យសៅហ្មងដល់ពូជវង្សត្រកូលរបស់យើងយ៉ាងនេះក៏មាន ។ ៥-អ្នកប្រមឹកសុរាវសាស្រវឹងស៊ប់ហើយ, ឥតមានសេចក្ដីអៀនខ្មាសទេ, អវយវៈដែលគេត្រូវការលាក់បិទបាំង ខ្លួនឯងទៅជាស៊ើយ លាតបញ្ចេញអាការកិរិយាឲ្យគេឃើញជាក់ស្ដែង, ជួនកាលដើរស្រែករេឡេរឡូប៉ប៉ាច់ប៉ប៉ោចតាមផ្លូវ សំដែងអាការដោតតាបឲ្យគេឃើញជាក់ស្ដែងក៏មាន, ខ្លះស្រវឹងក្អួតដួលដេកស្ដឹងស្ដូក ហាក់ដូចជាស្លាប់ តាមចន្លោះផ្លូវឬសំយាបផ្ទះគេក៏មាន, មិនតែប៉ុណ្ណោះ ចិត្តធំព្រហើនហ៊ានកាប់សំឡាប់ឥតកោតញញើត យ៉ាងនេះក៏មាន។ ៦ អ្នកប្រមឹកសុរា ឈ្មោះថាជាអ្នកធ្វើបំណោះវិជ្ជាព្រមទាំងប្រាជ្ញាស្មារតីឲ្យអន់ថយក្រោយចុះទៅជាដកប, បើគិតការអ្វី ឬនឹងធ្វើការអ្វី ច្រើនធ្វើប្រថុយទៅទាំងកំពេលឥតដឹងខុសត្រូវ ។ សេចក្ដីដែលបានពណ៌នាមកនេះ ឈ្មោះថាជាប្រធាននៃ. សេចក្ដីវិនាសក្នុងលោកនេះ ។

អ្នកប្រមឹកសុរា មិនមែនធ្វើឲ្យខាតក្រឹមតែខ្លួនឬគ្រួសាររបស់ខ្លួនទេ, បានឈ្មោះថាធ្វើជាតិនិងប្រទេសឲ្យខាតថែមទៀត ។ ហេតុនេះ អស់លោក-អ្នកកាន់អំណាចគួរតែផ្ចាញ់ផ្ចាលបំបាត់សភាពប្រមឹកបែបនេះក្នុងស្រុកនីមួយ ៗ កុំឲ្យមាន ទើបបានសេចក្ដីចំរើន ។

ឧបាយមុខទី ២- បានដល់ការដើរលេងក្នុងវេលាយប់ខុសកាល គឺក្នុងពេលដែលគេត្រូវសំរាកសម្ងំដេកពួន , ខ្លួនដើរលេងផ្ដេកមមកតាមច្រកល្ហកផ្លូវតូចធំហួសពេលវេលា ចោលប្រពន្ធកូនទ្រព្យសម្បត្តិនៅផ្ទះ, ឥតមានអ្នកណាគ្រប់គ្រងរក្សា, ឈ្មោះថាបើកឱកាសឲ្យដល់សត្រូវ គឺចោរ ប្រមាថមើលងាយដល់ទ្រព្យសម្បត្តិក៏មាន , ជួនកាលខ្លួនឯងដើរទៅ ក៏ត្រូវទទួលគ្រោះថ្នាក់មានពស់ខ្លែបខាំទិចជាដើម រងទុក្ខវេទនាក៏មាន, ពុំនោះសោតមានអ្នកផងគេរង្កៀសសង្ស័យថាអ្នកនេះហែដើរយប់ ប្រហែលជារកស៊ីដោយផ្លូវទុច្ចរិតទេដឹង ? ជួនកាលមានចោរលួចឆក់ដណ្ដើមទ្រព្យសម្បត្តិរបស់គេពិត ហើយរត់ភៀសគេចខ្លួនបាត់ទៅ , ទទួលគេឃើញខ្លួនដើរទៅ , ម្ចាស់ទ្រព្យគេក៏ចោទប្រកាន់ខ្លួនថាជាចោរ ហើយក៏គំរាមចាប់ចងធ្វើទុក្ខទោស ដាក់ពិន័យ ជាប់គុកច្រវាក់បង់ទ្រព្យធនធានក៏មាន , នេះហើយឈ្មោះថាជាប្រធាននៃសេចក្ដីវិនាស ព្រោះដើរលេងក្នុងវេលាយប់ខុសកាល ។

ព្រះទេពសត្ថា

គិម-គូរ (ចន្ទមង្គលោ)

(នៅមានត)

# ដំណឹងគួរដឹងខ្លះគួរគិតខ្លះ

ដំណឹងពីហាណូយ កាលពីថ្ងៃទី ៩ មេសា ១៩៥៤ ថាឧត្តមសេនីយ៍ វ៉ោ-ង្វៀន-យ៉ាប់ (វៀតមិញ) បានបញ្ជូនកងទាហានចំនួន ២០.០០០ បន្ថែមទៀត ដើម្បីវាយបន្ទាយ ដៀន-បៀន-ភូ ។ កងអគ្គបញ្ជាការទាហានបារាំងសែស ថ្លែងថាបានបញ្ជូនកងអាកាសយាន ដែលនៅសល់ចូលវាយស្កាត់ដំណើរហើយ ប៉ុន្តែដោយពពកអណ្តែតទាបពេក ហើយខ្យល់បក់ខ្លាំង ទើបធ្វើឲ្យកិច្ចប្រតិបត្តិការមិនសូវបានផល ។

ចំណែកការប្រយុទ្ធនៅសមរភូមិ ឌៀន-បៀន-ភូ ក្នុងថ្ងៃទី ៩ មេសា នោះ កងទាហានបារាំង-វៀតណាម បានចូលវាយគ្នាដោយដំពុះទុង ជាមួយកងទាហានវៀតមិញ ដែលផលទីបំផុតគឺដេញកំចាយពួកវៀតមិញ ឲ្យថយចេញពីកន្លែងបំណាតអាកាសយាន ដែលពួកវៀតមិញឃុំគ្រងទៅបាន ។ ដំណឹងនៅថ្ងៃដដែលនេះថា នៅពេលប្រយុទ្ធគ្នានោះ កងទ័ពបារាំង-វៀតណាមបានកំចាយទ័ពវៀតមិញអស់មួយកងពលតូច ។

* *
*

ដំណឹងពីវ៉ាស៊ីងតោនផ្សាយមកថា ក្នុងពេលថ្លែងចំពោះទីប្រជុំគណៈកម្មាធិការប៉ែកការបរទេសនៃសភាតំណាងរាស្ត្រកាលថ្ងៃទី ៦ មេសា នោះ លោក ហ្សន ហ្វូស្ដើ ដ័លឡេស រដ្ឋមន្ត្រីស្ដីការក្រសួងការបរទេសអាមេរិក បានបញ្ជាក់ថា ការដែលពួកកុម្មុយនិស្តចិនចូលរួមក្នុងយុទ្ធនាការនៅ ឌៀន-បៀនភូ ពេលនេះ, មានលក្ខណៈសំខាន់មិនបាច់ឲ្យមានសង្ស័យថា ពួកកុម្មុយនិស្តមិនមែនចូលធ្វើអន្តរាគមក្នុងសង្គ្រាមឥណ្ឌូចិនឡើយ ។ លោកដ័លឡេសបានបន្តសេចក្តីថា ក្នុងការស៊ើបសួរយកការណ៍បាននៅពេលចុងក្រោយបង្អស់ បានសេចក្តីថា ការចូលរួមនៃពួកកុម្មុយនិស្តក្នុងសង្គ្រាមឥណ្ឌូចិន ដូចតទៅនេះ ៖

១) ឧត្តមសេនីយ៍ ចិនកុម្មុយនិស្ត ឈ្មោះ លី ចេង ហ៊ូ បានចូលមកបញ្ជាការប្រចាំ ក្នុងកងបញ្ជាការនៃសេនាធិការកងទ័ពវៀតមិញនៅឌៀនបៀន-ភូ,

២) មានទីប្រឹក្សាតិកនិកខាងទាហាន ដែលជាជាតិចិនប្រតិបត្តិការនៅក្រោមបង្គាប់នៃ ឧត្តមសេនីយ៍ លី ចេង ហ៊ូ ក្នុងកងបញ្ជាការវៀតមិញប្រហែល ២០ នាក់ ។ ក្រៅពីនេះមានទីប្រឹក្សាតិកនិកអំពីកងទ័ពចិនក្រហមប្រចាំនៅតាមកងពលផ្សេង ៗ នៃកងទ័ពវៀតមិញទៀតផង ។

៣) មានការបាត់ចែងតាំងខ្សែទូរស័ព្ទឡើងជាពិសេសជុំវិញ ប៉មឌៀន-បៀន-ភូ ហើយភ្នាក់ងារទាំងនេះសុទ្ធតែជាតិចិនដែរ,

៤) មានការយកកាំភ្លើងតស៊ូអាកាសយានខ្នាត ៣៧ ម.ម. យ៉ាងច្រើនមកតាំងសង្ហានៅជុំវិញ ឌៀនបៀន-ភូ ។ កាំភ្លើងទាំងនេះមានវិធីប្រើដោយកំឡាំង

រ៉ាដារ ដែលអាចបាញ់ទំលាយដុំពពកទៅបានផង ។ កាំភ្លើងទាំងនេះគឺជារបស់កុម្មុយនិស្ត ទាំងអស់ ។

៥) ក្នុងអាណាខេត្រ ឌៀន-បៀន-ភូ វៀតមិញមាន រថយន្តសំរាប់ដឹកនាំអាវុធយុទ្ធភ័ណ្ឌ, សម្ភារៈផ្សេង ៗ ចំនួន ១០០០ គ្រឿង ដើម្បីជាកំឡាំងក្នុងការប្រយុទ្ធ ទឹងទ័ពបារាំង-វៀតណាម ។ បណ្ដាកាមីយ៉ុងទាំង នេះមានពាក់កណ្ដាល ទើបនឹងបញ្ជូនមកពីចិនក្រហម កាលពីថ្ងៃទី ១ មីនា ១៩៥៤ ហើយអ្នកបើកបរទាំង អស់ គឺ ភ្នាក់ប្រចាំនៅក្នុងកងទ័ពចិនកុម្មុយនិស្ត ។

៦) ក្រៅពីការជួយអនុគ្រោះដោយប្រការផ្សេងៗ ដូចពោលមកហើយ, ពួកចិនក្រហមមានបញ្ជូនកាំ- ភ្លើងកាណុងធំនិងយុទ្ធសម្ភារៈ ព្រមទាំងគ្រឿងយុទ្ធោ- បករណ៍ផ្សេង ៗ ឲ្យពួកវៀតមិញថែមទៀតជាច្រើន ។

ដំណឹងពីបាងកកថា កាលពីថ្ងៃអាទិត្យ ទី ២៨ មីនា ១៩៥៤ សេនាប្រមុខពិបុលសង្គ្រាម ក្នុងឋានៈ ជារដ្ឋមន្ត្រីការសេដ្ឋកិច្ចជាតិ បានបញ្ជាឲ្យចាប់អ្នកជំ- នួញ ៦ នាក់ ដែលជាប់ពិរុទ្ធថា រួមគ្នាប្រែប្រួលគុណ ភាពស្រូវដែលបញ្ជូនទៅលក់ក្នុងប្រទេស នៅក្នុង ចក្រភពអង់គ្លេស ដរាបដល់រដ្ឋាភិបាលថៃត្រូវគេតវ៉ា ។ មួយទៀត អ្នកជំនួញទាំងនេះបានប្រើវិធីគេចវេះពី ដាស៊ីជ្ជាតវែផង ។

ចំពោះការនេះ បាននាំឲ្យរដ្ឋាភិបាលថៃ ត្រូវ ខាតប្រាក់ចំណូលក្នុងមួយឆ្នាំ ៗ ច្រើនលានបាត ។

ដំណឹងចាប់នេះ បានផ្សាយបន្តមកទៀតថា ក្រោយដែលបានពិនិត្យ សំណុំរឿងរួចហើយ, ក្រុម ប៉ូលិសបានអនុញ្ញាតឲ្យនៅក្រៅឃុំ ៥ នាក់ ដោយ មានថ្លៃប្រកាន់ខ្លួនម្នាក់ៗ ៣ លានបាត ៗ ចំណែក ម្នាក់ទៀត ត្រូវឃុំទុកព្រោះបានបដិសេធពាក្យចោទ ទាំងមូល ។

ប្រភពដដែលនេះបានបញ្ជាក់ថា មុនមានការ ចាប់ខ្លួនទាំង ៦ នាក់ គឺសេនាប្រមុខពិបុល្យ បាន បញ្ជូនរឿងរ៉ាវផ្សេងៗ ឲ្យប៉ូលិសសន្តិបាល និងអ្នកជំ- នាញការបញ្ជី អ្នកជំនាញការសហករណ៍ និងអ្នក ជំនាញការធញ្ញពាណិជ្ជ នាំគ្នាប្រឹក្សានឹងរួមគ្នាធ្វើ ការស៊ើបអង្កេតអស់វេលា ២ ខែ ដរាបដល់បានលក្ខឋាន ត្រឹមត្រូវទើបបញ្ជាឲ្យចាប់ ។

* *
*

ដំណឹងពីបាងកកមកទៀតថា ក្រុមប៉ូលិសថៃ ដែលមាន ឧត្ដមសេនីយ៍ ផៅ-ស្រីយានន្ទ ជាអធិបតី បានមានបង្គាប់យ៉ាងដាច់ខាតដល់ប៉ូលិសខ្លួនទៅ ឲ្យ ប្រឹតខាងការចរាចរតាមវិថី ថា នរណាបើករថយន្ត ឬចក្រយានយន្ត ៗលៗ លឿនហួសក្ដី, ពួសូរថង់ ត្រចៀកខ្លាំងក្ដី ត្រូវដកសំបុត្រអនុញ្ញាតភ្លាមមួយ រំពេច កុំយល់មុខនរណាឲ្យសោះ ។

*
* *

ដំណឹងពីបាងកកថា នៅថ្ងៃទី ១៣ មេសា ១៩៥៤ នៅវត្តបាងហ្វាង ឌិត ( តិស្សក្ខុកាកម ) មាន ធ្វើពិធីសម្ពោធព្រះពុទ្ធរូបមួយអង្គ ព្រះកន្ទ ១ ម៉ែត្រ

៧៨ សង្ទីម៉ែត្រ, កំពស់ ២ ម៉ែត ២២ សង្ទីម៉ែត្រ ដែលឧបាសកម្នាក់ឈ្មោះ ថង់ហ- សេងសុត្ថា (សៈមមិត្ត-យន្ត) បានមានសទ្ធា សាងឡើងដើម្បីនាំយកមកប្រតិ-ស្ថានក្នុងប្រទេសខ្មែរ ។ ក្នុងឱកាសពិធីនេះ មាន មហោស្រពលេងមួយរាត្រី ។

*
* *

ប្រកពថ្ងៃដំណឹងបារាំងសែស បានថ្ងៃថា ដោយថ្ងៃទី ២១ ទសភា ១៩៥៤ នៅថ្ងៃបញ្ចប់គ្រប់ ដោយជុំវិញនៃមិត្តសម្ពន្ធដ៏ស្និទស្នាល រវាងបារាំងនិង អង់គ្លេសនោះ នៅថ្ងៃនោះ នឹងមានការធ្វើយ៉ាង មហោឡារ ។

ចំពោះពិធីនេះ ខាងអង់គ្លេសបានអញ្ជើញលោក ហ៊្សកបឹស្ហូលរដ្ឋមន្ត្រីការបរទេសបារាំងសែសរួចស្រេច ហើយ ។ គេស្មានថា នៅប៉ារីស ក៏មុខជានឹងមាន អញ្ជើញឥស្សរជនខាងអង់គ្លេស មកក្នុងពិធីនេះ ដែរ ។

មហា សម-ម៉ង

ដោយហេតុទស្សនាវដ្ដីលេខ ៣ ខែមីនា ចេញ យឺត បានជាខ្ញុំយកដំណឹងក្នុងខែមេសាមកចុះ សូម អភ័យពីសំណាក់អស់លោកអ្នកអាន

បណ្ណាធិការ ហួតហៀម

---

# បុណ្យមាឃបូជា

ពិធីបុណ្យ មាឃបូជានេះ ជាបុណ្យពុទ្ធសា-សនប្បវេណីមួយ ដែលពុទ្ធសាសនិកជនទាំងឡាយ គ្រប់ប្រទេសក្នុងពិភពលោក តែងនិយមរាប់អានធ្វើ បុណ្យនេះគេតែងតែធ្វើនៅវេលាយប់ថ្ងៃ ១៥ កើតខែ មាឃរាល់តែឆ្នាំ ដោយហេតុការនឹករលឹកដល់ថ្ងៃ ដែលព្រះគោតមសម្ពុទ្ធបរមគ្រូ ទ្រង់ប្រកាសដាក់អាយុ សង្ខាររបស់ព្រះអង្គក្នុងថ្ងៃនោះ, ក្រោយដែល មារ ចិត្តបាបចូលទៅអារាធនាព្រះអង្គ ឲ្យស្ដេចយាងចូល បរិនិព្វាន ។

សេចក្ដីដំណាលថា ពេលនោះមារចិត្តបាបបាន ចូលក្រាបបង្គំគាល់ព្រះសម្ពុទ្ធ ហើយក្រាបបង្គំទូល ថា "បពិត្រព្រះគោតមបរមសម្ពុទ្ធ សូមព្រះអង្គ ស្ដេច យាងចូលនិព្វានទៅ, ព្រះអង្គកុំគង់នៅយូរពេកឡើយ, ព្រោះក្នុងបឋមពោធិកាលនោះ ខ្ញុំព្រះអង្គបានចូលមក អារាធនាព្រះអង្គម្ដងដែរ, តែព្រះអង្គពុំព្រមទទួល ដោយអាងហេតុថា ព្រះអង្គបានត្រាស់ដឹងនូវអនុត្តរ-សម្មាសម្ពោធិញ្ញាណពិតមែនហើយ តែព្រះអង្គពុំ ទាន់បានប្រដៅសិស្សគណ ឲ្យចេះដឹង នូវព្រះសទ្ធម្ម របស់ព្រះអង្គនៅឡើយ ឥឡូវនេះ ព្រះអង្គបាន ប្រដៅសិស្សគណ ៗ បានចេះដឹងធម៌វិន័យរបស់ព្រះ អង្គច្រើនក្រាស់ក្រែលណាស់ដែរហើយ ថែមទាំង សិស្សគណ ទាំងនោះនិមន្តផ្សាយព្រះ សទ្ធម្មរបស់ព្រះ

អង្គ នៅតំបន់នានា សព្វគ្រប់អស់ហើយ ដូច្នេះគួរតែព្រះអង្គស្ដេចយាងចូលនិព្វានទៅ ។

គ្រានោះ ព្រះសម្ពុទ្ធទ្រង់ទទួលអារាធនារបស់មារបិត្តបាប ដោយមានព្រះពុទ្ធដីកាថា "ម្នាលមារបិត្តបាប ចូរអ្នកកុំមានសេចក្ដីខ្វល់ខ្វាយច្រើន ក្នុងការបង្ខំឲ្យតថាគតចូលនិព្វាននោះពេកឡើយ, នៅតែ ៤ ខែទៀតទេ តថាគតនឹងចូលនិព្វានដោយពិត" ។ គ្រាន់តែព្រះសម្ពុទ្ធជាម្ចាស់ មានព្រះបន្ទូលដូច្នេះភ្លាម ស្រាប់តែមហាប្រឹថពី កក្រើកញាប់ញ័រឡើង ទាំងទឹកក្នុងមហាសមុទ្រក៏បញ្ចេញរលកធំៗ ឡើងដែរក្នុងពេលនោះ ។ ចំណែកមារ បិត្តបាប និមិត្តតែបានឮព្រះពុទ្ធដីកាដូច្នេះហើយ ក៏មានចិត្តរីករាយក្រៃលែង អរក្រេបក្រុប ហើយក៏អន្តរធានបាត់ពីទីនោះទៅ ។ ឯព្រះមហាអានន្ទត្ថេរ លុះបានឃើញមហាបថវីកម្បនាដូច្នេះហើយ មានសេចក្ដីឆ្ងល់ហើយចូលទៅក្រាបបង្គំទូលសួរព្រះសម្ពុទ្ធ អំពីហេតុអស្ចារ្យនៃមហាបថវីកម្បនានោះ ។ ព្រះសម្ពុទ្ធ ក៏មានព្រះបន្ទូលថា "អំបាញ់មិញនេះ មារបិត្តបាបបានចូលមកអារាធនាតថាគតឲ្យចូលនិព្វាន តថាគតក៏បានយល់ព្រមតាមពាក្យអារាធនា របស់គេទៅហើយ" ។ ព្រះមហាអានន្ទត្ថេរ លុះបានឮព្រះសម្ពុទ្ធ មានព្រះដំរាស់ដូច្នេះហើយ ក៏មានសេចក្ដីខ្សឹកខ្សួលយំសោក អាឡោះអាល័យព្រះសម្ពុទ្ធជាខ្លាំង ហើយក៏អារាធនាសុំកុំឲ្យព្រះសម្ពុទ្ធយាងចូលនិព្វានឆាប់ឆ្អាប់ឡើយ សូមឲ្យគង់នៅអស់កាលជាយូរអង្វែងតទៅទៀត ព្រោះថាបើព្រះអង្គគង់នៅយូរទៅទៀត នាំឲ្យមានប្រយោជន៍ដល់សព្វសត្វលោកពន់ពេកណាស់ សូមព្រះអង្គស្ដេចគង់នៅសិន" ។

ព្រះសម្ពុទ្ធទ្រង់មានព្រះបន្ទូលតបថា "តថាគតមិនយល់ព្រមតាមពាក្យអារាធនារបស់អ្នកទេ! កំហុសនេះ "ពុំមែនកើតមានមកពីនរណា ក្រៅពីអ្នកឡើយ, គឺបំពោះមកពីអានន្ទឯងនេះជាពិតប្រាកដ ព្រោះនៅពេលមុន តថាគតបានទេសនាប្រាប់អ្នកថា ឥទ្ធិបាទធម៌ទាំង ៤ បើអ្នកណាមួយចំរើនបានហើយ, អ្នកនោះ បើមានប្រាថ្នា ចង់រស់នៅ, អាចរស់នៅ អស់ ១ កប្ប (អាយុកប្ប) ឬច្រើនជាងមួយកប្បទៅទៀត ក៏បាន, ចំណែកតថាគតចំរើនបានហើយ, ឥទ្ធិបាទធម៌ទាំង ៤ នោះ បើតថាគតចង់រស់នៅ អស់ ១ កប្ប ឬច្រើនជាង ១ កប្បទៅទៀតក៏បានដែរ, តថាគតបានឲ្យឱកាស (គឺឲ្យន័យបំភ្លឺឲ្យយល់) ដល់អ្នកហ្នឹងនេះម្ដង ជា ២ ដង រហូតអស់វារៈ ៣ ដង អ្នកនៅតែមិនយល់ មិនអារាធនាឲ្យតថាគតគង់នៅសោះ, បើអ្នកអារាធនាឲ្យតថាគតគង់នៅលើកទី ១ តថាគតមិនព្រម, លុះដល់អ្នកអារាធនាលើកទី ២ តថាគតនឹងយល់ព្រមមិនលែង បើអ្នកអារាធនាឲ្យតថាគតគង់នៅលើកទី ២ តថាគតមិនព្រម, លុះដល់អ្នកអារាធនា ឲ្យតថាគតគង់នៅលើកទី ៣ តថាគតមុខជានឹងយល់ព្រមតាម

ពាក្យអារាធនារបស់អ្នកជាមិនខាន, នេះអ្នកឥតបានអារាធនា ឲ្យតថាគតគង់នៅសោះ, ធ្វើម្ដេចបើតថាគតយល់ព្រមតាមពាក្យអារាធនា របស់មារចិត្តបាបទៅហើយ" ។

បើតាមន័យត្រង់នេះ យើងជាពុទ្ធសាសនិកជនដែលបានរស់នៅក្នុងរវាង ព.ស. ២៤៩៦-៧ នេះ ប្រហែលជាបានទាន់ព្រះពុទ្ធជាម្ចាស់ ហើយនឹងបានស្ដាប់ព្រះសទ្ធម្មផ្ទាល់ពីព្រះឱស្ឋ របស់ព្រះអង្គគង់បានសំរេចមគ្គ-ផល ផងទៀតក៏មិនដឹងមើលទៅ, បើប្រសិនជាពេលនោះ ព្រះមហាអានន្ទត្ថេរបានអារាធនាព្រះសម្ពុទ្ធឲ្យគង់នៅហើយព្រះអង្គយល់ព្រមតាមផង ។

សួរថា: នាកាលព្រះសម្ពុទ្ធ កំពុងសំដែងឥទ្ធិបាទទាំង ៤ រួចហើយទ្រង់ព្រះទានឱកាសដល់ព្រះមហាអានន្ទត្ថេរ អំពីហេតុដែលព្រះអង្គអាចបន្តព្រះជន្មាយុ ទៅឲ្យរស់ ១ កប្បឬច្រើនជាង ១ កប្បក៏បានដែរនោះ ចុះហេតុម្ដេច បានជាព្រះមហាអានន្ទត្ថេរភ្លាយគំនិតមិនអារាធនានិមន្តព្រះសម្ពុទ្ធ ឲ្យស្ដេចគង់នៅ ឲ្យរស់ ១ កប្បឬជាច្រើនជាង ១ កប្បទៅ ?

ឆ្លើយថា: បានជាព្រះមហាអានន្ទត្ថេរពុំបានអារាធនានិមន្តព្រះសម្ពុទ្ធឲ្យស្ដេចគង់នៅឲ្យរស់ ១ កប្បឬឲ្យច្រើនជាង ១ កប្ប នោះ, ព្រោះពេលនោះព្រះមហាអានន្ទត្ថេរ ត្រូវមានចិត្តបាបកំពុងជ្រែកដែរ បានជាភ្លាយគំនិតគិតពុំឃើញ ។

ហេតុដូច្នេះហើយ បានជាថ្ងៃ ១៥ កើត ខែមាឃ រៀងរាល់ឆ្នាំ ពុទ្ធសាសនិកជនទាំងឡាយតែងចាំទុកក្នុងចិត្តមិនភ្លេចនូវមាឃបូជានេះ ហើយដកខ្លួនចេញអំពីកង្វល់ផ្សេងៗ យកគ្រឿងសក្ការៈទៅកាន់វត្តអារាម ធ្វើសក្ការបូជា ចំពោះព្រះរតនត្រ័យ នឹងស្ដាប់ធម៌ទេសនា ដើម្បីជាបុណ្យកុសលរបស់ខ្លួន; ព្រោះថ្ងៃនោះ នៅពេលដដែលនោះដែរ ព្រះមហាអានន្ទត្ថេរ បានទទួល អារាធនានិមន្តព្រះសម្ពុទ្ធឲ្យស្ដេចគង់នៅតទៅទៀត តែព្រះអង្គពុំព្រមទទួលអារាធនាឡើយ ដោយមានព្រះបន្ទូលបន្ថែមទៀតជាព្រះពុទ្ធោវាទ ថា: "ម្នាលអានន្ទ ធម៌នឹងវិន័យ តថាគតបានសំដែងប្រាប់អ្នករាល់គ្នាសព្វគ្រប់អស់ហើយធម៌នឹងវិន័យនេះ នឹងបានជាគ្រូជាអាចារ្យរបស់អ្នករាល់គ្នាហើយ, ត្រូវអ្នករាល់គ្នាគោរពប្រតិបត្តិឲ្យត្រឹមត្រូវតាមធម៌នឹងវិន័យនោះចុះ អ្នករាល់គ្នានឹងបានទទួលផលល្អចំពោះខ្លួនឯង ព្រោះថាខ្លួនជាទីពឹងរបស់ខ្លួនឯងចំណោមអំពើអាក្រក់-ល្អគ្រប់យ៉ាង , អ្នកដទៃក្រៅពីខ្លួន ធ្វើម្ដេចនឹងជាទីពឹងបាន" ។

អ៊ុក-ផង់

## ការប្រឡងបេក្ខសមណៈ

ការប្រឡងជ្រើសរើសពួកនិស្សិតសមណៈដែលមានសញ្ញាបត្រសាលាបាលីរងដែនក្នុងសាំងស៊ុន ដូចមានតទៅនេះ-

កាលពីថ្ងៃទី ២៦ ដល់ ២៨ ខែកុម្ភៈឆ្នាំ ១៩៥៤

នៅសាលាបាលីរងវត្តសារាវ័នតេជោ ភ្នំពេញ មាន ការជួបជុំពួកព្រះសង្ឃមេប្រយោគ និងសិស្សដែលប្រុងប្រឡង ដើម្បីចូលរៀនក្នុងឋានៈជាសិស្សស្ដាប់នៅសាលាបាលីជាន់ខ្ពស់ ក្រោមការឧបត្ថម្ភរបស់លោក ឡាំ-ឯម អតីតចៅហ្វាយខេត្រឃ្លាំង ហើយជាអធិបតីរងនៃពុទ្ធសាសនបណ្ឌិត្យដែនកូស័ងស៊ីន តាមប្រកាសលោកគួវែរណើរហ្សេណេរ៉ាល់លេខ ៣៨៥០ ចុះថ្ងៃ ២៥ កញ្ញា ១៩៤៣ អនុញ្ញាតឲ្យតាំងក្រសួងពុទ្ធសាសនបណ្ឌិត្យរង នៅប្រទេសយៀកណាម កូ-សាំងស៊ីនប៉ែកខាងត្បូង... ។

ការប្រឡងនោះ ចាប់តាំងពីម៉ោង ៨ ដល់ម៉ោង ១១ និង ៣០ នាទី ឯព្រឹក និងវេលាល្ងាចតាំងពីម៉ោង ១៥ ដល់ម៉ោង ១៨ ថ្ងៃខាងលើនោះ, ក្រុមសន្និបាតមានសមាសភាពដូចរៀបរៀងតទៅនេះគឺៈ



១-ព្រះញាណកោសលញាណ. ឈឹន វត្តលង្កា អធិបតី

២-ព្រះគ្រូសោភ័ណ សេង-នាង វត្តឧណ្ណាលោម សមាជិក

៣- ព្រះបាឡាត់ឃោសរក្ខិត ហ៊ុយ-អ៊ូច វត្តសារាវ័ន សមាជិក

៤- ព្រះមហា វិញ-គៀង ( ជំនួស ) វត្តឧណ្ណាលោម សមាជិក

៥-ព្រះមហា ថាច់-ឯក វត្តសារាវ័ន „

៦-ព្រះមហា ខេមរិន្ទ វត្តមហាមន្ត្រី „

៧-ព្រះមហា ជា-អៀ វត្តលង្កា លេខាធិការ

តាំង ៧ អង្គនេះបានជួបជុំតាមកាលបរិច្ឆេទ ដូចខាងលើរួចហើយ ទើបលោកអធិបតីរងនៃពុទ្ធសាសន-បណ្ឌិត្យ ប្រគល់វិញ្ញាសាប្រឡងតាំង ៥ ប្រយោគ ដែលច្រកស្រោមបិទគាក់ល័ខយ៉ាងជិតស្និទ្ធ ឥតមានរង្គៀសប្រគេនទៅលោកអធិបតីមេប្រយោគ ។ ក៏បើកចំកាសប្រឡងសិស្សចំនួន ៤២ រូបដែលអង្គុយតាមលំដាប់លេខរៀង សម្រាប់ខ្លួនតាំងពីលេខ ១ ដល់លេខ ៤២ ទើបលោកមេប្រយោគបើកវិញ្ញាសាបង្ហាញ រួចហើយហៅឲ្យសរសេរតាមសូត្រ, លំដាប់តមកឲ្យសិស្សប្រែបាលីលោកប្រយោគ , អធិប្បាយគាថា, តែងសេចក្ដីខ្មែរ,ធ្វើចំណោទនព្វន្តទាំង ៤ ប្រយោគសុទ្ធតែសរសេរទាំងអស់ ឥតមានសួរផ្ទាល់មាត់ទេ, ក្រដាសប្រឡង

ទាំងនោះសឹងបិទឈ្មោះសាម៉ីខ្លួនអ្នកប្រឡងយ៉ាងជិតតាមបញ្ញត្តិច្បាប់, លុះសិស្សសរសេររួចរាល់ទាំង ៤ ប្រយោគហើយ ក្រុមមេប្រយោគពិនិត្យតាមកម្លាំងប្រាជ្ញារបស់សិស្សដែលសរសេរជាប់នៅនឹងក្រដាសរួចហើយឲ្យពិន្ទុពីសូន្យ(១)ដល់ម្ភៃ(២០), សិស្សដែលបានពិន្ទុបូករួមយ៉ាងតិចត្រឹម ១១០ ពិន្ទុ ទើបទុកជាបានការ ។

## លទ្ធផល

បណ្ដានិស្សិតទាំង ៤២ រូបដែលបានចូលប្រឡងទាំងពេលព្រឹក-ល្ងាច ក្នុងថ្ងៃដូចខាងលើ លុះរួចរាល់ហើយ ចំនួនសិស្សដែលបានពិន្ទុគួរដល់ការមានតែចំនួន ២០ រូប ដូចមានរាយនាមក្នុងបញ្ជី នឹងសេចក្ដីកត់ហេតុជូនទៅលោក អធិបតីរងនៃពុទ្ធសាសនបណ្ឌិត្យសព្វគ្រប់ស្រាប់ ។

ឯក្នុងទីនេះ មិនបានសរសេររាយនាមទៀតទេ សូមអត់ទោស ។

សូមសរសើរយោបល់នៃក្រសួងពុទ្ធសាសនបណ្ឌិត្យរង នឹងសមាគមសិក្សាវិទ្យាល័យខេមរៈដែនកូសាំងស៊ីនដែលមានលោក ឡាំ-ឯម ជាប្រមុខបេះរៀបចំធ្វើការបណ្ដុះបណ្ដាលអក្សរសាស្ត្រ, វប្បធម៌, ការ្យធម៌, រក្សាទំនៀមទំលាប់របស់ខេមរវង្សឲ្យរស់នៅរីកក្នុងទីចង្អៀតដរាបដល់សព្វថ្ងៃ, នេះជាអំពើដ៏ប្រសើររកបានដោយក្រក្នុងលោក ។

សូមជូនសព្ទសាធុការពរក្នុងឱកាសចូលឆ្នាំថ្មី ចំពោះបងប្អូនរួមជាតិអ្នកដែនកូសាំងស៊ីន ទាំងព្រះសង្ឃគ្រហស្ថ ឲ្យបានសុខចំរើនសព្វ ៗ កាល ។

សួស្ដីខ្មែរអ្នកដែនកូសាំងស៊ីន !

ព្រះញាណកោសល ញាណ-ឈឹន

---

# ទំនៀមទម្លាប់ និង ឧត្តមប្រយោជន៍

## របស់ទំនៀមទម្លាប់

ផ្សាយចេញពីក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរនៅពុទ្ធសាសនបណ្ឌិត្យ

ប្រវេណី ធម្មតា សណ្ដាប់ សណ្ដាប់ធ្នាប់ បែបបទ ហៅថា "ទំនៀម", សេចក្ដីដែលធ្លាប់លំអានដែលមានត ៗ គ្នាមក នាំឲ្យចាំបាន ហៅថា "ទម្លាប់" ; រួមពាក្យទាំងពីរម៉ាត់នេះ ចូលគ្នា បានជាពាក្យមួយបទ ហៅថា "ទំនៀមទម្លាប់" គឺ ប្រវេណី ធម្មតា សណ្ដាប់ សណ្ដាប់ធ្នាប់ បែបបទ ដែលមនុស្សរាល់ប្រទេស រាល់សង្គម ទូទៅទាំងពិភពលោក ធ្លាប់បានប្រព្រឹត្ត រឿយ ៗ យ៉ាងថ្នឹកសម្រាប់ជាតិ សម្រាប់ប្រទេសរៀង ៗ ខ្លួន ។

ទំនៀមទម្លាប់, ទាក់ទងដោយកិច្ចការផ្សេង ៗ ជាអនេកប្រការ មាននការនិយាយស្ដី ការស្លៀកពាក់ ការបរិភោគ ការប្រើប្រាស់ ការមង្គល ការបួងសួង ការបន់ស្រន់ ការបូជា ការសាសនា ការរចនា របរចិញ្ចឹមជីវិត ល្បែង របាំ តូរ្យតន្ត្រី និង ចម្រៀង ជាដើម ។

ទំនៀមទម្លាប់នេះហើយ ដែលជាគ្រឿងសំគាល់អារ្យធម៌របស់ជាតិ របស់ប្រទេសនីមួយ ៗ ។

មនុស្សមានសញ្ជាតិ នឹងប្រទេសជាមួយគ្នា តែងមានទំនៀមទម្លាប់ត្រូវគ្នា ផ្សេងជាតិ ផ្សេងប្រទេសតែងមានទំនៀមទម្លាប់ផ្សេង ៗ គ្នា ជាដរាប ។ ប៉ុន្តែជួនកាល ប្រទេសផ្សេង ជាតិផ្សេង បែរជាមានទំនៀមទម្លាប់ ស្រដៀងគ្នាដោយអន្លើខ្លះក៏មាន ព្រោះប្រទេសនៅជិតឬឆ្ងាយពីគ្នា តែមានផ្លូវគមនាគមន៍ ប្រស្រ័យទាក់ទងគ្នាទៅវិញទៅមករឿយ ៗ ព្រោះកាន់សាសនាជាមួយគ្នា ឬព្រោះប្រទេសតូច ៗ ដែលមានទំនៀមទម្លាប់ទន់ទាប តែងតែចម្លងយកទំនៀមទម្លាប់ របស់ប្រទេសធំ ៗ ដែលមានទំនៀមទម្លាប់ខ្ពង់ខ្ពស់ ទៅប្រព្រឹត្តតាមច្រើនយ៉ាងជាធម្មតា, ដូចប្រទេសខ្មែរយើងសម័យអង្គរ ដែលជាប្រទេសមហាអំណាចមួយក្នុងអាស៊ីទ្វីប នោះប្រទេសជិតខាងបានចម្លងយកបែបផែនទំនៀមទម្លាប់ខ្មែរ ទៅប្រព្រឹត្តតាមជាច្រើនប្រភេទ; ឧទាហរណ៍ ដូចសម័យដែលប្រទេសខ្មែរចំរើន ប្រទេសសៀមបានចម្លងយកបែបគ្រឿងពិណពាទ្យពីខ្មែរយើងទៅប្រើតាម, ដល់សម័យប្រទេសសៀមចំរើនឡើង ខ្មែរយើងត្រឡប់ជាហៅគ្រឿងនេះថា "គ្រឿងសៀម" ទៅវិញ ។

ដោយហេតុ ក្នុងប្រទេសនីមួយ ៗ តែងមានទំនៀមទម្លាប់ខ្លះសាត្រឡប់ចុះឡើង ដូចរៀបរាប់មកនេះ បានជាប្រជាជនជាម្ចាស់ប្រទេសពិបាកសង្កេតឲ្យស្គាល់ច្បាស់នូវដើមកំណើតទំនៀមទម្លាប់របស់ខ្លួន ពន់ពេកលុះតែអ្នកប្រាជ្ញខាងប្រជាតិវណ្ណនា ដែលបារាំងហៅថា "ethnographie" គឺវិជ្ជាសាស្ត្រពណ៌នាអំពីទំនៀមទម្លាប់ស្រុក នឹងអ្នកប្រាជ្ញខាងជាតិវង្សវិជ្ជា ដែលបារាំងហៅថា "cthnagraphie" គឺវិជ្ជាប្រៀបធៀបអំពីទំនៀមទម្លាប់ជាតិផ្សេង ៗ ទើបអាចស្រាវជ្រាវរកដើមកំណើតទំនៀមទម្លាប់របស់ប្រទេសជាតិនីមួយៗ ឲ្យឃើញពិតបាន ។

ចន្ទាល ជាគោលសំខាន់របស់រទេះ ឬរថ ព្រះរាជា ជាគោលសំខាន់របស់ប្រទេស យ៉ាងណា; ទំនៀមទម្លាប់ ជាគោលចារិកសំខាន់របស់ប្រទេសជាតិនីមួយ ៗ យ៉ាងនោះ ។ បណ្ឌិតទាំងឡាយយល់ថា បើទំនៀមទម្លាប់របស់ជាតិណាគង់នៅ, ជាតិនោះក៏គង់នៅ, ទំនៀមទម្លាប់ជាតិណារលត់, ជាតិនោះក៏រលត់ ជាប្រាកដពុំខាន ។

ដើមហេតុ ដែលកើតជាទំនៀមទម្លាប់ សម្រាប់ប្រទេសជាតិនីមួយៗឡើង មិនមែនកើតដោយរហ័សភ្លាមៗទេ គឺកើតឡើងដោយសន្សឹម ៗ ហើយទើបចម្រើនឡើងជាលំដាប់ ដូចវ័យរបស់មនុស្ស ។ ព្រោះហេតុនេះ ចំពោះទំនៀមទម្លាប់ល្អ ៗ ដែលកើតបានជារូបរាងច្រើនគត ច្រើនសតវត្សមកហើយ មិនគួរបណ្ដោយឲ្យបាត់ទៅវិញទេ គួរតែស្រាវជ្រាវកត់ត្រារក្សាទុកឲ្យគង់ឋិតថេរតទៅ សម្រាប់ជាគោលចារិករបស់ជាតិ ជាព្រំដែនរបស់ប្រទេសនីមួយ ៗ ។

ការបានកត់ត្រា បានស្រាវជ្រាវរកដើមកំណើតទំនៀមទម្លាប់ប្រទេសជាតិរបស់ខ្លួនតាមជំនាន់ទុក , លោកទុកដូចបានថតរូបរបស់ខ្លួនទុកតាមវ័យ ឲ្យដឹងថា កាលពីក្មេងយ៉ាងណា ដល់ចាស់ទៅជាយ៉ាងណា ; ការមិនបានកត់ត្រាទំនៀមទម្លាប់ប្រទេសជាតិរបស់ខ្លួនទុក, ដូចមានរូបហើយពុំបានថតទុកសោះ ដល់រូបនោះចាស់ទៅឬធ្វើមរណកាលទៅ នឹងសាបសូន្យបាត់ទៅ រកកេរ្តិ៍ដំណែលជាកស្តុតាងគ្មាន ។ ប្រទេសណា មានឯកសារកត់ត្រាទំនៀមទម្លាប់ប្រទេសជាតិ - របស់ខ្លួនទុក ដោយមានដើមកំណើតនិងគោលចារឹកច្បាស់លាស់ល្អប្រជាជនកើតក្រោយ ក្នុងប្រទេសនេះ ទើបអាចដឹងដើមកំណើតទំនៀមទម្លាប់ប្រទេសជាតិ - ខ្លួនបានសព្វគ្រប់ ។

ទំនៀមទម្លាប់មានទាំងល្អទាំងអាក្រក់ ជាធម្មតា ទំនៀមទម្លាប់ល្អ ជាទំនៀមទម្លាប់គួរធ្វើឲ្យចម្រើនឡើង ទំនៀមទម្លាប់អាក្រក់ ជាទំនៀមទម្លាប់គួរតែកែប្រែឲ្យល្អឡើង, ប៉ុន្តែទោះបីយ៉ាងណាក៏គួរកត់ត្រាស្រាវជ្រាវរកឲ្យដឹងដើមកំណើតទាំងអស់ហើយគួររក្សាទុកជាគ្រឿងចំណាំសម្រាប់ឲ្យដឹងថា ទំនៀមទម្លាប់ណាមួយដែលសម័យបុរាណដូចម្តេច, ហើយតទៅមុខទៀតបានប្រែប្រួលទៅជាយ៉ាងណា ។

អារ្យប្រទេសទាំងពួងក្នុងលោកសម័យបច្ចុប្បន្នគេសុទ្ធតែតាំងភ្នាក់ងារមួយក្រុមជំនុំសម្រាប់ធ្វើការជាប់មុខតែខាងការកត់ត្រាស្រាវជ្រាវរក្សាទុក នូវឯកសាររឿងទំនៀមទម្លាប់ប្រទេសជាតិរបស់គេ ទាំងល្អទាំងអាក្រក់ៗ ឯប្រទេសខ្មែរយើងសព្វថ្ងៃនេះ នឹងខានមានក្រុមនេះពុំបានទេ បានជាព្រះរាជរដ្ឋាភិបាលបានតាំងក្រុមបែបនេះមួយក្រុមឡើង ហៅថា "ក្រុមជំនុំទំនៀមទម្លាប់ ស្រុកខ្មែរ" ។ ក្រុមជំនុំនេះ មានមន្ត្រីធ្វើការនៅក្រុងភ្នំពេញនាពុទ្ធសាសនបណ្ឌិត្យក្រសួងធម្មការមានមុខងារធ្វើការខាងកត់ត្រាស្រាវជ្រាវប្រមែប្រមូល រកនឹងរក្សាទុក នូវឯកសាររឿងទំនៀមទម្លាប់ផ្សេងៗ របស់ខ្មែរតែក្រុមជំនុំនេះមហាជនជាតិខ្មែរពុំទាន់ស្គាល់គ្រប់គ្នានៅឡើយទេ ដោយជនខ្លះដែលយល់ថា ការស្រាវជ្រាវកត់ត្រារក្សាទុក នូវឯកសាររឿងទំនៀមទម្លាប់ ជាការមានប្រយោជន៍សំខាន់សម្រាប់ប្រទេស ក៏យកចិត្តទុកដាក់ទទួលស្គាល់, ជនខ្លះដែលយល់ថាជាការឥតប្រយោជន៍ ក៏ព្រងើយកន្តើយ ។ តាមសេចក្តីយល់របស់អ្នកសរសេររឿងនេះថា ក្រុមនេះគួរតែពង្រីកឲ្យចម្រើនធំឡើង ដើម្បីស្រាវជ្រាវរកទំនៀមទម្លាប់ របស់យើងដែលមានពីបុរាណមកឲ្យអស់សព្វគ្រប់ ព្រោះសព្វថ្ងៃនេះ អារ្យប្រទេសទាំងពួងគេបានពង្រីកក្រុមនេះ បានសិក្សារឿងនេះ សម្រាប់ប្រទេសជាតិគេគ្រប់ប្រទេសហើយ, ប្រទេសខ្លះគេបានតាំងផ្ចៀតមកសិក្សានូវទំនៀមទម្លាប់ខ្មែរយើងថែមទៀតផង ហេតុនេះខ្មែរយើងមិនសមបីព្រងើយកន្តើយនឹងរឿងទំនៀមទម្លាប់របស់ខ្មែរទេ គួរតែនាំគ្នាសិក្សារឿងនេះឲ្យចេះដឹងច្រើន កុំឲ្យបាត់ជន

បរទេស ៗ

ក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ សូមប្រកាសដល់មហាជនរួមជាតិថា

ចាប-ពិន

(នៅមានត)

## ដំណើរ

សម្តេចព្រះមហាសុមេធាធិបតី ជ. ណ., ជោតញ្ញាណោ សង្ឃនាយកគណៈ មហានិកាយ និមន្តទៅកាន់ប្រទេសភូមា

តពីលេខ ២ មក



ឧបាសក ជាច្រើននាក់ស្លៀកពាក់ដូច ៗ គ្នា ឈរជាពីរជួរសងខាងជណ្តើរឡើង មានទាំងអ្នកវាយរគាំងអ្នកផ្លុំស័ង្ខ អ្នកកាន់គ្រឿងសក្ការៈ ដង្ហែសម្តេចប្រទក្សិណព្រះចេតិយថ្វាយបង្គំគ្រប់ទិសទាំង៤ រួចនិមន្តសម្តេចចូលទៅកាន់សាលាសំណាក់ប្រគេនគេសជ្ជៈរួចថតព្រះចេតិយនឹងចីវរ ហើយទើបរៀបក្បួនហែបន្តដំណើរទៅទៀត ទៅដល់វត្តសាសនៈយុគតា (សាសនប្ហាយា ? ដែលជាទីសំណាក់ការបណ្តោះអាសន្ន នៃសហភាពពុទ្ធសាសនាប្រទេសភូមា, ព្រះភិក្ខុសង្ឃនឹងលោករដ្ឋមន្ត្រីក្រសួងធម្មការ ព្រមទាំងពួកឧបាសកឧបាសិកា ចាំទទួលនិមន្តចូលទៅកាន់ធម្មសភា សាលាជួបជុំខមស្ការ



សុំសីលប្រាំអំពីសម្តេច ៗ សម្តេចបានសន្ទនាប្រាស្រ័យអស់កាលគួរហើយ

លុះដល់ពេលព្រលប់ ទើបនិមន្តទៅកាន់កុដិសំណាក់ ជាកុដិឈើទើបនឹងសង់ហើយថ្មី មានបន្ទប់មួយៗ ដោយឡែកៗ មានគ្រឿងប្រើប្រាស់គ្រប់សព្វ មាន អ្នកបំរើប្រចាំយប់ថ្ងៃជានិច្ច ។

ថ្ងៃទី ២០ មីនា, ពេលព្រឹក លោក ទុង្វិន ប្រធាន ពុទ្ធិកសមាគមប្រទេសភូមា និមន្តទៅទទួលចង្ហាន់នៅ គេហស្ថានរបស់លោក ហើយជួបជុំជាមួយនឹងព្រះ សង្ឃជាច្រើនរូប មានទាំងលោករដ្ឋមន្ត្រីក្រសួងធម្ម- ការនឹងឧបាសកជំនាញការ ចំនួន ២៧ នាក់ផង បាន ពិគ្រោះប្រឹក្សាគ្នា អស់កាលយ៉ាងយូរព្រមព្រៀងឲ្យ ឈ្មោះ ការផ្ទៀងផ្ទាត់ធម៌វិន័យដែលបម្រុងនឹងធ្វើ

ប.ស. (នៅមានត)



## បុណ្យព្រហ្មទាន

ថ្ងៃទី២០មីនា១៩៥៤ នៅយ៉កណ្ដាលនៃ សាលាបាលីជាន់ ខ្ពស់គេបានឃើញ ទង់ជាតិនឹងទង់សា- សនា បក់រវិចប្រពាក់ ប្រពួនលើគ្នាៗ ក្នុង រាត្រីនោះពន្លឺភ្លើងអគ្គិសនី ក៏បញ្ចេញរស្មីយ៉ាងអង់ អាច ហាក់ដូចពេលដែលព្រះអាទិត្យកំពុងតាំងនៅ អាចញ៉ាំងទឹកចិត្តនៃប្រជាជនប្រុសស្រី ចាស់ ក្មេងជា ពុទ្ធបរិសទ្យ ឲ្យរីករាយយ៉ាងក្រៃលែងៗ ពិធីនោះ បានចាប់ផ្ដើមនៅពេលម៉ោង២០ យប់ មាននិមន្តព្រះ សង្ឃចំរើនព្រះបរិត្ត នឹងទេសនាតាមបវេណីៗគេបាន ឃើញឯកឧត្ដម សំ-ញាណ រដ្ឋមន្ត្រីក្រសួងធម្មការនឹង អស់លោកអ្នកមុខអ្នកការជាច្រើនដោយមិនបានបញ្ចេញ នាមអញ្ជើញទៅជាអធិបតី ក្នុងវិធីបុណ្យនោះដែរ អស់លោក ធំ-តូចទាំងអស់ មានគារវភាពយ៉ាងប្រ- ពៃសមតាមឋានៈជាអ្នកកាន់ព្រះពុទ្ធសាសនាប្រាកដ មែនៗ ក្នុងរាត្រីនោះ គេបានបញ្ចប់ពិធីនៅម៉ោង ២៣,៣០ នាទី ។

ថ្ងៃអាទិត្យទី ២១ មិនា១៩៥៤វេលាម៉ោង ១៦,៣០ នៅតាមបង្កាន់ដៃនៃយ៉សាលាបាលីជាន់ខ្ពស់គេឃើញ រណ្ដាប់ព្រហ្មទាន, ដែលគណៈកម្មការបាន ចាត់ចែង

ទៀនដោយមានក្រដាសក្ដិធ្មុះពណ៌ខ្ចប់ជាលំអនួរបាច់ ផ្កាកដាក់ដំរៀបគ្នាជាជួរតាមលំដាប់តិចច្រើន; ក្រុមអភិបាលនិងទីប្រឹក្សានៃសមាគមមិត្តសាលាបាលីព្រមទាំងសមាជិកសមាជិកាជាច្រើន បានមកជួបជុំក្នុងពេលជាមួយគ្នានោះដែរៗ ព្រះសង្ឃទាំងឡាយ ទើបនឹងប្រឡងជាប់ទីមហាឧត្ដមវិជ្ជាបរិយត្តិ ក៏បាននិមន្តមកគង់ដង្ហែតាមលំដាប់លើកៅអី ដែលគណៈកម្មការរៀបបំរុងៗក្នុងខណៈជាមួយគ្នានោះ នឹងជាបន្ទាប់មកលោក ហ៊ូកុម្មិស៊ែរប្រេចាំប្រទេសកម្ពុជា នឹងលេខាធិការផ្ទាល់អញ្ជើញមក បន្តិចទៀតបានទូតអាមេរិកាំង បានអញ្ជើញដល់ជាបន្ទាប់នឹងគណៈរដ្ឋមន្ត្រីគ្រប់ដំណែង បានអញ្ជើញមកទទួលអំណរក្នុងពិធីនោះដែរ ៗជិតដល់ម៉ោង ១៧ ហើយ គណៈរដ្ឋមន្ត្រីប្រធានសមាគមមិត្តសាលាបាលី ប្រធានពុទ្ធិកសមាគមក្រុមអភិបាល ទីប្រឹក្សាសមាគមមិត្តសាលាបាលី ប្រុងប្រៀប នឹងចាំទទួលព្រះរាជដំណើរនៃព្រះករុណាជាម្ចាស់ជីវិត ដែលស្ដេចទ្រង់យាងជាអធិបតីក្នុងពិធីបុណ្យនោះៗ សម្ដេចព្រះមហាសុមេធាធិបតី, សម្ដេចព្រះធម្មលិខិតឧត្ដមប្រឹក្សា, ជំណាងសម្ដេចព្រះសុធម្មាធិបតី, ព្រះតេជព្រះគុណពោធិវង្សចាងហ្វាងសាលាបាលីជាន់ខ្ពស់ នឹងព្រះមហាថេរជាសាស្ត្រាចារ្យមានព្រះតេជៈព្រះគុណ ព្រះមហាព្រហ្មមុនី-អ៊ុំ ចាងហ្វាងរង ព្រះពុទ្ធវង្ស កៅ-សំម ព្រះគ្រូញាណសត្ថា ប៉ែន-សុខ ជាដើមបានរៀបចំព្រះអង្គនឹងទទួលព្រះរាជដំណើរដោយសន្ធិសុខជាស្ថាពរ ម៉ោង ១៧ដល់ហើយពួកភ្លេងនឹងកងយោធា ទាំងឡាយប្រុងប្រៀបខ្លួន បន្តិចមកគេបានឃើញព្រះរាជទីនាំងផ្ទាល់ព្រះអង្គមកដល់ ភ្លេងជាតិក៏បន្លឺឡើង ក្លស់ក៏បានបើកថ្វាយចំពោះព្រះប្រិយមហាក្សត្រ គារវភាពនៃអស់លោក-អ្នកមុខអ្នកការទាំងឡាយ ក៏បានធ្វើឡើងដោយព្រមគ្នាតែម្ដង ក្នុងពេលនោះ, ចំពោះព្រះភូមិន្ទ, ព្រះរាជាស្ដេចយាងតាមលំអាននៃកម្រាលព្រហ្មចៀមដែលមានគំនរផ្កាបាចពាសពេញ ទ្រង់យាងជាន់សន្ទឹមៗ រហូតដល់ព្រះសុវណ្ណគោប្ជុះដែលគណកម្មការបានរៀបចំទុកថ្វាយៗ គេចាំបានថាព្រះប្រិយមហាក្សត្ររបស់យើងនេះ ពេញជាវីរបុរសសាសនូបត្ថម្ភដោយប្រាកដ ព្រះអង្គទ្រង់ប្រកបដោយព្រះកាយភាពដ៏ទន់ចំពោះព្រះមហាថេរគ្រប់អង្គក្នុងខណៈដែលទ្រង់បានជួបប្រទះ អបចាយនកិច្ចនេះ ព្រះអង្គមិនមែនមានចំពោះតែព្រះសង្ឃប៉ុណ្ណោះទេ សូម្បីប្រជារាស្ត្រចាស់ព្រឹទ្ធាចារ្យទាំងឡាយក៏ទ្រង់មានព្រះកាយភាពដូច្នោះដែរ (នេះជាប្រវេណីនៃព្រះមហាវីរក្សត្រជាទីស្រឡាញ់របស់យើង) ពិធីចែកព្រហ្មទានក៏ផ្ដើមឡើង ៗ

ជាលើកដំបូងលោកអធិបតីសមាគមមិត្តសាលាបាលី បានអានសុន្ទរកថាមួយថ្វាយព្រះរាជា ៗ

បន្ទាប់ពីនេះព្រះពោធិវង្សហួត-តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់ បានអានសុន្ទរកថាមួយថ្វាយព្រះមហាក្សត្រ នឹងក្រើនរំលឹកដល់និស្សិតដែលទើប

និងប្រឡងចេញ ។

បន្ទាប់មកទៀតឯកឧត្តម សម-ញាណ ក្រសួងធម្មការ បានចាប់កាន់នាមព្រហ្មទាន ដោយមាននាមព្រហ្មទានព្រះមហាក្សត្រជាប្រមុខ ព្រះមហាក្សត្រទ្រង់ស្ដេចយាងប្រគេនដោយផ្ទាល់ព្រះអង្គ បន្ទាប់មកលោកកុមីស្សែរ ឯកឧត្តមនាយករដ្ឋមន្ត្រី ថានទូត រដ្ឋមន្ត្រីនិងអ្នកមុខអ្នកការគ្រប់ដំណែង ការប្រគេនព្រហ្មទានបានបញ្ចប់នៅម៉ោង ១៧,៤០ ។

មុននឹងស្ដេចយាងទៅកាន់ព្រះរាជដំណាក់វិញ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានទ្រង់ថ្លែងសុន្ទរកថាមួយ ក្នុងនាមនៃព្រះអង្គជាព្រះរាជាធិបតី ដែលមានសេចក្ដីគួរជាប់យកមកប្រតិបត្តិ កុំបីឲ្យឃ្លៀងឃ្លាតចាកមធុរក់ទ នោះម៉ោង ១៨, ២៥ ព្រះភូមិន្ទស្ដេចទ្រង់យាង ត្រឡប់ទៅកាន់ព្រះរាជវាំងវិញ លោកហូកុមីស្សែរ ប្រតិភូ និងគណៈរដ្ឋមន្ត្រី ក៏បានស្ដេចយាង និងអញ្ជើញត្រឡប់វិញជាបន្ទាប់ ៗ នោះដែរ គេបានបញ្ចប់ពិធីនេះនៅម៉ោង ១៩គត់ ។

ព្រះសង្ឃដែលទើបនឹងបានឋានៈ ជាមហាបរិយត្តិឧត្តមវិជ្ជា លោកមានព្រះទ័យពេញប្រៀបដោយសេចក្ដីរីករាយ ដោយបានពិនិត្យឃើញអាការញញឹមជាប់ពុំដាច់, សូមអស់លោកជាម្ចាស់ព្រហ្មទានទាំង-ឡាយជឿជាក់ថា នេះហើយជាទានមួយយ៉ាងប្លែក ដែលយើងបានធ្វើចំពោះព្រះសង្ឃ ដោយមិនរើសមុខត្រូវបដិគ្គាហកៈ ប្រកបដោយសេចក្ដីសោមនស្សយ៉ាងនេះផង នោះតើទានរបស់យើងនឹងមានរស្មីបែបណាទៅ ! ។ ខ្ញុំនឹកក្នុងចិត្តថា សមាគមមិត្តសាលាបាលី ពិតជាសមាគមទំនុកបំរុងព្រះពុទ្ធសាសនាដោយពេញមុខ ខ្ញុំជាអ្នកស្រឡាញ់សាសនាដែរ ខ្ញុំត្រូវតែឧបត្ថម្ភសមាគមនេះ ដោយពេញកម្លាំង ។ មួយទៀតដល់ឆ្នាំ ១៩៥៥ ខ្ញុំនឹងធ្វើព្រហ្មទានឲ្យប្លែកអស្ចារ្យជាងព្រហ្មទានឆ្នាំ ១៩៥៤ នេះទៅទៀត ។

សុន្ទរកថាទាំងបីនឹងជូនទៅទំព័រខាងមុខ

---

## ប្រវត្តិសាស្ត្រប្រទេសកម្ពុជា សង្ខេប
## ពីសម័យបុរាណ មកដល់
## សម័យបច្ចុប្បន្ន.

ប្រទេសកម្ពុជា គឺជាព្រះរាជអាណាចក្រមួយ ឧប្បត្តិឡើងពីបុរាណកាល ដែលប្រជាជន មកពីប្រទេសឥណ្ឌា, សាសន៍នេះកាន់យកនូវអារ្យធម៌តាមប្រវេសន៍ នៃប្រទេសឥណ្ឌា និងប្រទេសឥណ្ឌូឡាំង (ឥណ្ឌូណេស៊ី) រៀបចំប្រទេសនេះឲ្យនៅក្រោមឥទ្ធិពលនៃអារ្យធម៌ប្រទេសឥណ្ឌា ដោយបាននាំមកឲ្យប្រទេសនេះ នូវភាសានិងអក្សរសាស្ត្រសំស្ក្រឹត, ព្រហ្មញ្ញសាសនានិងពុទ្ធសាសនា ។

អ្នករាតត្បាតទាំងនេះបានបង្កើតឡើង, នៅក្នុងសតវត្ស ទី ១ នៃ គ.ស., ជាប្រទេសមួយដែលអ្នក

ទេសចរចិនហៅថា ហ្វូណន គឺប្រទេសកម្ពុជា នាបច្ចុប្បន្នកាលនេះ ។ ដែលរាប់បញ្ចូល ទាំងប្រទេសវៀតណាមខាងត្បូង (កូសាំងស៊ីន), ប្រទេសលាវ និងប្រទេសម៉ាឡាយូ (ប្រទេសម៉ាឡេស៊ី)។ ព្រះរាជអាណាចក្រខ្មែរ ហៅហ្វូណន បានតាំងរាជធានីរបស់ខ្លួន នៅទីក្រុងបាសាក់ (ក្នុងប្រទេសលាវសព្វថ្ងៃ) ។

នៅសតវត្សទី ៦ នៃ គ.ស. ក៏ចាប់ផ្ដើមជំវត្តន៍ យកបានទីដីទំនាបនៃទន្លេមេគង្គទាំងប៉ុន្មាន ហើយផ្លាស់ឈ្មោះពីហ្វូណនមកជាព្រះរាជអាណាចក្រកម្ពុជា ហើយដែលមានវឌ្ឍនភាពដោយឆាប់រហ័ស ។

ចាប់តាំងពីសតវត្សទី ៨ នៃ គ.ស. មក ខ្មែរទាំងឡាយ ក៏មកតាំងភូមិភាគនៃបឹង កសាងដ៏អស្ចារ្យ នូវកំពែងនិងនគរវត្ត ដែលមាននគរធំជារាជធានី ។ ឯប្រាសាទនគរវត្ត បានកសាងឡើងនៅសតវត្សទី ១២ នៃ គ.ស. ដែលជាសញ្ញានៃអារ្យធម៌របស់កម្ពុជា ។ ប៉ុន្តែនៅសតវត្សរ៍ទី ១៥ នៃ គ.ស. ពួកសៀមបានមកលុកដណ្ដើមយកអង្គរធំបាន ហើយការធ្លាក់ចុះក៏បណ្ដាលឲ្យមានឡើងបន្តិចម្ដង ៗ ប្រទេសកម្ពុជាក៏ត្រូវខ្វះ (ការគេស៊ី) ដោយថៃឡង់ម្ខាងនិងពួកវៀតណាមម្ខាង ។ តាមសន្ធិសញ្ញាពីឆ្នាំ ១៨៦៣, ប្រទេសបារាំងបានចុះហត្ថលេខា នៅក្រុងឧត្តុង្គ រវាងព្រះបាទសម្ដេចព្រះនរោត្តមនិងលោកឧត្តមនាវី ឡាក្រង់ឌីយែរ ដាក់ជាប្រតិកត្តូរ៉ាត់ (អាណាព្យាបាល) និងជួយការពារសត្រូវដែលចូលមកបៀតបៀន ប្រទេសនេះ ។ ប្រទេសបារាំងបានសុំឲ្យប្រទេសថៃឡង់ប្រគល់ខេត្ត ៣ គឺៈ បាត់ដំបង, សៀមរាប, និងស៊ីសោភ័ណ មកប្រទេសកម្ពុជាវិញ តាមសន្ធិសញ្ញាពីឆ្នាំ ១៩០៧[១] ។

## ការដើរទៅកាន់ឯករាជ្យនៃប្រទេសកម្ពុជា

តាមកិច្ចព្រមព្រៀងបណ្ដោះអាសន្នចុះថ្ងៃ ៧ មករា ១៩៤៦ លក្ខន្តិកៈនៃអាណាព្យាបាល បានលប់ចោល ហើយបើកឲ្យប្រទេសកម្ពុជា មានអធិបតេយ្យខាងក្នុងឡើង ។ ក្រុមរាជការជាតិទំនើបទាំងឡាយត្រូវរៀបចំឡើង ដោយមានការជួយដឹកនាំនៃទីប្រឹក្សាបារាំង ដូចជាក្រុមសិក្សាធិការ, សុខាភិបាល, សាធារណៈការ, សុរិយោដី, កសិកម្ម, រុក្ខាទឹងគង្គា, ការចិញ្ចឹមសត្វ, ពាណិជ្ជកម្ម និង ឧស្សាហកម្ម ។

តាមសេចក្ដីប្រកាសឲ្យប្រើ នូវរដ្ឋធម្មនុញ្ញចុះថ្ងៃ ៦ ឧសភា ១៩៤៧, លទ្ធិសម្បូណ៌ាញាសិទ្ធិរាជ ក៏បានផ្លាស់មកជា បរិមិតាញាសិទ្ធិរាជ អាស្រ័យរដ្ឋសភា ចាប់ពីថ្ងៃនោះតមក, អំណាចទាំងឡាយចេញមកពីព្រះមហាក្សត្រិយ៍ត្រង់រាជ្យ គឺប្រើក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍, ដោយរដ្ឋសភា (អំណាចនីតិបញ្ញត្តិ)

---

១ អាណាខេត្តទាំង ៣ នេះនិងអាណាខេត្តឯទៀតរបស់ប្រទេសលាវ ដែលបានប្រគល់ទៅឲ្យប្រទេសថៃឡង់ ដោយសេចក្ដីបន្តិតបន្តំនៃប្រទេសជប៉ុន, តាមសន្ធិសញ្ញាចុះថ្ងៃ ៩ ឧសភា ១៩៤១ នោះ ។ ក្រោយសង្គ្រាមលោកទី ២ ដែលផុតរលត់ទៅ, មានការបើកសន្និសីទនៅក្រុងវ៉ាស៊ីនតោន (សហរដ្ឋអាមេរិក) តាមបទបញ្ជាបារាំងសៀមចុះថ្ងៃ ១៧ មករា ១៩៤៧ បានព្រមព្រៀងគ្នាប្រគល់អាណាខេត្តខ្មែរទាំង ៣ មកឲ្យខ្មែរវិញនិងអាណាខេត្តលាវមកឲ្យលាវវិញ។

គណៈរដ្ឋមន្ត្រី (អំណាចនីតិប្រតិបត្តិ) តុលាការ (អំណាចតុលាការ) ។ មានតែរដ្ឋសភាប៉ុណ្ណោះទេ ដែលមានបុព្វសិទ្ធិ ប្រើអំណាចនីតិបញ្ញត្តិបាន ។

សមាជិកទាំងឡាយនៃរដ្ឋសភា ត្រូវនៅក្នុងដំណែងត្រឹម ៤ ឆ្នាំ ដោយបានជ្រើសតាំងឡើងពីជនដែលមានអាយុយ៉ាងតិច ២០ ឆ្នាំតាមវិធីបោះឆ្នោតសាកលនឹងដោយចំពោះ ។ ខេត្តនីមួយ ៗ ត្រូវមានដំណាងរាស្ត្រម្នាក់ក្នុងចំនួនបណ្តារាស្ត្រមួយម៉ឺននាក់ ១០.០០០ នាក់ ឬភាគលើសជាងពាក់កណ្តាលពីចំនួននេះ ដែលបានចុះបញ្ជីបោះឆ្នោតដោយត្រឹមត្រូវ។ ខេត្តនីមួយ ៗ ត្រូវចែកជាមណ្ឌលបោះឆ្នោត ដែលក្នុងមណ្ឌលនីមួយ ៗ ត្រូវបោះទទួលជ្រើសដំណាងរាស្ត្រម្នាក់ ។ អ្នកមានសិទ្ធិជ្រើសតាំង ត្រូវបោះឆ្នោតជ្រើសយកបេក្ខជនណា ដែលខ្លួនចូលចិត្ត ហើយដែលបានជាប់ឆ្នោត, កាលណា បើបានឆ្នោតច្រើនជាងគេដោយដាច់ខាត ។

ក្រុមប្រឹក្សាព្រះរាជអាណាចក្រ (មានបែបផែនដូចជាព្រឹទ្ធសភាចាស់ ឬ ដូចប្រឹក្សាសាធារណរដ្ឋនៅប្រទេសបារាំងនាបច្ចុប្បន្ននេះ) គ្រាន់តែជាអង្គការមួយសំរាប់ជាទីប្រឹក្សាច្បាប់ប៉ុណ្ណោះ។ សមាជិកនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រមាន ២៤ រូបត្រូវព្រះមហាក្សត្រិយ៍ចាត់តាំងដោយជ្រើសយកក្នុងបណ្តាព្រះរាជវង្សានុវង្សនៃព្រះអង្គ

សមាជិក ២ រូបត្រូវរដ្ឋសភាជ្រើសតាំងយកក្រៅពីសមាជិករបស់ខ្លួន ។

សមាជិក ៨ រូប ដែលជាតំណាងក្រុងភ្នំពេញនិងភូមិភាគទាំង ៧ នៃព្រះរាជអាណាចក្រ ។

សមាជិក ៨ ជាតំណាងវិជ្ជាជីវៈផ្សេងដែលត្រូវជ្រើសតាំងដោយបោះឆ្នោតចំពោះនឹងតាមសំបុត្រ ។

សមាជិក ៤ រូប ជាតំណាងអ្នករាជការទាំងឡាយ ក៏ដូច្នោះដែរ ។

ក្រោយបំផុត, តាមសន្ធិសញ្ញាបារាំងខ្មែរដែលបានចុះហត្ថលេខានៅក្រុងប៉ារីស នៅថ្ងៃ ៨ វិច្ឆិកា ១៩៤៩ ប្រទេសកម្ពុជាត្រូវបានជារដ្ឋឯករាជ្យក្នុងក្របខណ្ឌនៃសហភាពបារាំង ។

ដោយហេតុនេះ ប្រទេសកម្ពុជា ជារដ្ឋប្រជាធិបតេយ្យ អាស្រ័យរដ្ឋធម្មនុញ្ញ ។ ព្រះមហាក្សត្រគ្រងរាជ្យ ទ្រង់ជាអគ្គប្រមុខនៃរដ្ឋ ។ អំណាចនីតិប្រតិបត្តិ ត្រូវរាជរដ្ឋាភិបាលជាអ្នកប្រើ ។ ព្រះអង្គទ្រង់មានព្រះរាជសិទ្ធិ ចាត់តាំងនាយករដ្ឋមន្ត្រី ។ ជ្រើសរើសរដ្ឋមន្ត្រីទាំងឡាយតាមស្ម័គ្រ កបង្កើតជាគណៈរដ្ឋមន្ត្រីឡើង ក្រោយដែលបានទទួលសេចក្តីទុកចិត្តពីរដ្ឋសភាហើយ ។

តមក, នៅចុងឆ្នាំ ១៩៥៣ តាមកិច្ចចរចារបារាំង-ខ្មែរ, ប្រទេសបារាំងក៏បានប្រគល់អធិបតេយ្យពេញបរិបូណ៌ ខាងតុលាការ, ក្រុមនគរបាល និងកងទ័ពមកប្រទេសកម្ពុជាជ្រះស្រឡះ ដោយស្នាព្រះហស្តនៃព្រះបាទសម្តេចព្រះនរោត្តម-សីហនុវរ្ម័ន ។

អ៊ុក-ផង់ ប្រែចាកអត្ថបទជាភាសាបារាំង

## ទំនប់ ១០ ឆ្នាំ

ចំនួន ៨ ឆ្នាំកន្លងមកហើយ ខ្ញុំបាននាំមិត្តភក្តិ ៣ នាក់ជិះរទេះសេះកំសាន្តបរកាត់ព្រៃឈើតាលខែត្រពោធិ៍សាត់ ដើម្បីទៅសំណាក់លេងផ្ទះមេព្រៃនៅតំបន់នោះ ។ ដើមឈើខ្ពស់ស្រោងត្រូវរន្ទាលដោយរស្មីក្រហមនៃព្រះអាទិត្យអស្តង្គតទៅហើយ ស្រាប់តែសេះរបស់យើងឈប់ឈឹកក្រញាញថយក្រោយ ព្រឺប្រែងក្រញាង បញ្ចេញសំរែកតក់ស្លុត ។ យើងនឹកព្រួយបារម្ភមួយរំពេចទើបនាំគ្នាគេចចុះពីលើរទេះភ្លាម តយគន់មើលតើមានការណ៍អ្វីជាមិនស្រួល ។ នៅមុខយើងឃើញមានកូនខ្ទមឈើបាក់បែកតូចមួយខ្ទេចប្រផេះមួយផ្ទុកពងពងក្រពើដើរឆ្លងប្រែងប្រាងលើបានកំបែក ប្រាប់ទំនងឲ្យស្មានបានថាប្រហែលជាខ្ទមអ្នកតា យើងនឹកថា សេះយើងផ្អើលព្រោះខ្ទមនោះឯង ។ ផ្លូវថ្នល់ផុតនៅមាត់ជ្រោះមួយត្រង់ទីនោះ ដីបាក់ធ្លាក់ទៅក្រោមជាថ្នាក់ៗ ហាក់ដូចជាជណ្តើរយក្ស ដល់ទៅបាតលើកជាក្លាយ៉ាងធំ ដែលកាត់ឡើងទៅមាត់ជ្រោះខាងណាយ, ពុំមានផ្លូវដែលបន្តដំណើរតទៅទៀតទេ ។

ចួនពេលនោះជាពេលព្រលប់យប់ទៅហើយ យើងនឹងវិលថយក្រោយវិញមិនបាន ទើបយើងត្រូវឈប់សំរាកចុងរាត្រីក្រោមផ្កាយនៅទីនោះ ទំរាំដល់ភ្លឺឡើងនឹងលៃលកតដំណើរទៅទៀត ។ ពេលនោះយើងដុតមែកឈើការពារខ្លួនៗ ប្រមាណជាកណ្តាលអាធ្រាត្រ សូរខ្សឹបខ្សៀវយ៉ាងចំឡែក ដាស់យើងឲ្យភ្ញាក់ព្រើតក្រោកសស្ទន់សស្ទាឡើង យើងប្រញាប់វៃភ្លើងឲ្យឆេះឡើងសន្ធោសន្ធៅ ព្រោះពន្លឺភ្លើងការខ្លាចឲ្យអន់កំឡាំង នាំគ្នាអង្គុយត្របោមក្បាលជង្គង់ផ្ទង់ចាំស្តាប់ដោយខ្វក់ខ្វល់ចិត្ត តើសូរស័ព្ទខុសធម្មតានោះលេចឮពីទីណាមក ។

ពន្លឺទៀនមួយអណ្តែតធ្លោពីមាត់ជ្រោះម្ខាង ទៅរលត់ឯមាត់ជ្រោះម្ខាង សូរខ្សឹបខ្សៀវដែលលាន់ឮឡើងជាថ្មី គេស្តាប់ថាអ្វីមិនបាន ដោយច្បាស់លាស់សោះ មួយសន្ទុះក៏ស្ងាត់ឈឹងសូន្យ, លំដាប់តមកសំឡេងទ្រហឹងស្ទុះចេញមកពីបាតជ្រោះ ឮសូរសំរែកមនុស្សហៅគ្នាស្រែកដៀងរបៀបឆ្លើយថា "ថាវ៉ើយ ត្រង់នេះត្រង់នោះហ៎ា" ដូចជាកំពុងធ្វើការដោយពួកដោយក្រុម ។ ដោយចង់រកមើលកំណើតសំឡេងនោះឲ្យបានដឹងច្បាស់លាស់ ទើបយើងនាំគ្នាទៅកាន់មាត់ជ្រោះ, តែគ្មានអ្វីកើតសោះ ងងឹតសូន្យ ៗ ប្រហែលជាសំឡេងពួកខ្មោចបិសាចដដែលគ្នាទេឬ? ទឹកភ័យយើងបោលញញាក់ញញ័ររមករកភ្លើងក្នុងយើងវិញ រហូតដល់ម៉ោង៤ភ្លឺទើបបាត់ស្ងាត់ ។

លុះដល់ភ្លឺព្រះអាទិត្យរះឡើងទើបអ្នករកជ័រម្នាក់សារស័ព្ទប្រាប់យើងអំពីសូរស័ព្ទចំឡែកកំបិទកំបាំងនោះ, ក្រោយដែលបានធ្វើឲ្យយើងស្រៀវសាច់មួយស្របក់ ក្នុងពេលដែលស្រាប់តែលេចធ្លោចេញពីព្រៃមកនោះ ដោយឥតឲ្យយើងដឹងខ្លួនជាមុន, គេនិទានឲ្យស្តាប់ដូចតទៅនេះ :

កាលពីព្រេងព្រឹទ្ធកន្លងយូរលង់ទៅហើយ មានមហាក្សត្រមួយព្រះអង្គគ្រប់គ្រងប្រជារាស្ត្រ ដោយទសពិធរាជធម៌ប្រកបដោយព្រះជន្មវស្សាច្រើនណាស់ទៅហើយ តែទ្រង់គ្មានព្រះរាជបុត្រនឹងគ្រងព្រះរាជវង្សនោះ ។ ប្រជាជន ដែលគោរពព្រះអង្គស្មោះដោយទេត្តា នាំគ្នាឡើងសូមមកុដរាជកុមារ ដើម្បីកុំឲ្យផុតរាជ្យតទៅ ប្រទេសនៅតែលតោល ឥតទីពឹងពុំនាក់ដូចមាន់ព្រាត់មេ ព្រះរាជាក៏ព្រមតាមសេចក្តីអង្វរសុំហើយទ្រង់មានព្រះបញ្ជាឲ្យអគ្គមហេសី រៀបពីការថ្វាយទេត្តាប្រាថ្នាព្រះរាជបុត្រ ព្រះរាជទ្រព្យ ត្រូវបរិច្ចាគចែកបាយជាទានដល់ស្មូមយាចក វត្តអារាមព្រមទាំងក្រោមដើមជ្រៃទាំងឡាយ បរិបូណ៌ដោយគ្រឿងផ្កាយពោរពាស ធូបហុយទ្រលោមគួចផ្សែងវិលវល់សម្បូរខៀវទៅកាន់អាកាសទេត្តារំជួលខ្លាំងបានប្រសិទ្ធិពរ តាមសេចក្តីបួងសួង ។ មិនយូរប៉ុន្មាន, ព្រះរាជកុមារល្អពណ៌រាយ ដូចព្រះចន្ទពេញបុណ៌មី ស្រស់ឆ្អិនឆ្អៅដូចមាសទឹក ១០ បានប្រសូតកណ្តាលសេចក្តីរីករាយកងរំពងពេញព្រះរាជអាណាចក្រទាំងមូល សប្បាយអឺកធឹក គ្រប់ផ្លូវគ្រប់ស្រុកគ្រប់ភូមិគ្រប់និគមជនបទ, អ្នកស្លូមទាន អ្នកខ្វាក់ខ្វិនក៏មានចំណែក ក្នុងការត្រេកអរសាទរជាមួយគេឯងដែរ ។

ព្រះរាជកុមារ ទទួលនូវសេចក្តីថ្នាក់ថ្នមដ៏វិចិត្រមានស្ត្រីបំរើជាច្រើននាក់នៅចាំបំរើ ច្រៀងបំពេ បីពរល់ទិវារាត្រី ព្រះវរមាតាបិតា ប្រស់ព្រំព្រះរាជបុត្រាជាបណ្តាច់បណ្តូលព្រះហឫទ័យ ដោយសេចក្តីស្នេហាយ៉ាងទន់ភ្លន់ជាទីបំផុត ។ លុះព្រះរាជបុត្របានចំរើនវ័យធំហើយទ្រង់បានជ្រើសរើសអាមាត្យចំនួន៥០នាក់អាយុស្រករ ។ គ្នា ក្នុងបណ្តាកូនមន្ត្រីទាំងឡាយឲ្យនៅគាល់បំរើជានិច្ច ។ សូម្បីប្រកបដោយសុខយ៉ាងឆ្នើមដូច្នោះ ព្រះរាជកុមារពុំមានឈ្លក់ក្នុងសម្បត្តិទាំងនោះទេ ទ្រង់ចូលចិត្តសិក្សាវិជ្ជាផ្សេង ៗ បង្ហាញឲ្យឃើញស្តែងថាទ្រង់ប្រកបដោយបញ្ញាវៀងវៃ គួរជាទីពឹងដ៏ត្រជាក់នៃប្រជារាស្ត្របានមែនហើយទ្រង់ពុំដែលហ៊ានប្រព្រឹត្តកន្លងវិន័យរបស់ព្រះរាជវង្សទេ ។ តែទោះបីទ្រង់ប្រាថ្នាយ៉ាងណាបានយ៉ាងនោះក៏ដោយ ព្រះរាជ-កុមារមិនអាចចុះទៅកាន់មាត់ស្ទឹង ដែលហូរទៀបព្រះរាជវាំងបានឡើយ ព្រោះហោរាបានទំនាយថ្វាយថា បើចង់ឲ្យព្រះនគរផុតចាកមហន្តរាយ ព្រះរាជ-កុមារមិនត្រូវយាងក្រសាលទីនោះ រហូតដល់ព្រះជន្ម១៥ វស្សា ទើបបិតាបានចាត់ឲ្យពល ១០០ នាក់យាមល្បាតជានិច្ច ។ ព្រះរាជកុមារតែងគង់លំហើយព្រះកាយ នៅមាត់ព្រះបញ្ជរ គយគន់ពីលើមហា-ប្រាសាទ នូវស្ទឹងស្រស់ញញឹមដែលហូរស្រេម ៗតាមដើមឈើ ខៀវបំព្រងដោយបន្ទប់ទក្រូងធំគួរឲ្យស្រណោះ! ស្ទឹងសោកនោះនៅជិតបង្កើយ តែហាក់ដូចជាស្ថិតនៅក្នុងលោកដទៃព្រោះទ្រង់ពុំដែលស្គាល់សោះ ។ ឆ្ងាយអើយសែនឆ្ងាយ ! ។ សកុណា

ជាតិហើរឆ្ងៀលធ្លាក់ចូលពីត្រើយខាងនោះ កាត់មកគគ្រញែកគគ្រញែលលេងជាសប្បាយក្នុងសួនព្រះរាជវាំង ហើយសាសព្ទសរសើរប្រាប់គ្នីគ្នានូវលំអអស្ចារ្យនៃគុនស្មឹងតូច រួចនាំពួកខាងណោះទៅទីរម្មណីយដ្ឋានខាងនោះៗ មនោគតិព្រះរាជកុមារគោភាវសន្ទោសន្ទៅទៀងក្តិងឹងជាប៉ុន្មានរយដងទេ ដែលទ្រង់បង់ស្ពះទៅរកតំបន់ពេញប្រៀបដោយសម្រស់ធំធេតឆាយនោះ, ប្រសិនបើមានស្លាបដូចបក្សីហ្ន៎! តែទ្រង់មិនអាចគេចឲ្យរួតបានឡើយ អំពីការរាំងរក្សានៃពួកអាមាត្យដែលបានទទួលបង្គាប់ជាដាច់ខាត ហើយដែលតាមទ្រង់គ្រប់កន្លែងពីដូចស្រមោល ។

(នៅមានត) ហោង-យ៉ាង

## រឿងតាជ្រា

តាជ្រា ជាមនុស្សចាស់ទុំ, ទៅណាមកណា គាត់តែងមានប្រអប់ថ្នាំជាប់ជានិច្ច ហើយមានប្រដាប់ប្រដាសម្រាប់ជក់សព្វគ្រប់ឥតខ្វះ គឺថ្នាំខ្លាំង - ស្លឹកសង្ក្រ-ក្រដាស់-ដែកកើង ៗ រាល់ថ្ងៃសីល គាត់មិនដែលខានទៅវត្តទេ ។ ពេលជួបជុំនៅវត្ត, អ្នកផងទាំងពួងគេតែងមកហោមរោមជុំវិញតាជ្រា សុំថ្នាំខ្លាំងគាត់ជក់គ្រប់គ្នា ព្រោះគេចូលចិត្តថាថ្នាំគាត់ឆ្ងាញ់ ។ ថ្ងៃមួយតាជ្រានឹកមួម៉ៅខ្លាំងថា អាដែងអស់នេះ វាគាងតែឯងមានថ្នាំឲ្យវាជក់ព្រមទាំងប្រដាប់ប្រដាសព្វគ្រប់ វាបេះតែនាំគ្នាមកកេមឯងជុំ ៗ រាល់តែថ្ងៃសីល, ថ្នាំឯង ១ ប្រអប់ៗ ទម្រាំតែសុំសីលរួចត្រឡប់ទៅផ្ទះវិញ គ្មានសល់ ១ សរសៃសោះ, បើវាលេងតែស្មៀតនេះ មើលទៅអញមុខជាដាច់សីលដាច់ពរអស់ហើយរុំ គ្មានអាណាមានឃ្លាំងថ្នាំសម្រាប់តែអាដែងគ្រប់គ្នានេះទេ ។ ថាហើយតាជ្រាក៏រំលឹកអ្នកទាំងពួងថា មនុស្សជក់វាមាន ៣ គឺ លោកជក់=គេមានប្រដាប់សម្រាប់ជក់សព្វគ្រប់ឥតខ្វះ; អ្នកជក់ = មានមិនគ្រប់ទេ គឺមាននេះខ្វះនោះ មាននោះខ្វះនេះ; អាជក់ = គ្មានអ្វីទាំងអស់ គឺហោលម្សៀតមារយាទថោក បានតែជំហាមគេ ហើយមានមាត់មានពាក្យថាខ្លួនចូលចិត្តៗ – ចំណែកឯងគិតតែចូលចិត្តៗ ទៅ, រួចគ្នាឯណោះ រលីងពីប្រអប់កុំឲ្យសល់១ សរសៃ ត្រឡប់ទៅផ្ទះវិញឲ្យប្រពន្ធគ្នាប្រទេចទៀត ។ អាដែងឯងទាំងអស់គ្នានេះសុទ្ធតែចូលក្នុងបទអាជក់ឥតសល់ម្នាក់ – ពីថ្ងៃនេះតទៅឯងរាល់គ្នា មើលចូលចិត្តទៀតទៅនាង បើបាន ១ សរសៃ គោត !ៗ

ញូង-សៀង

* * *

## រឿងកំសាន្ត

នាយទេស :– ពីព្រឹកមិញនេះ អញទិញឆ្នោតជាតិ ១ សន្លឹក, តាំងពីទិញហើយមកបែបដូចជាបេះតែធូនក្បាល, មើលទៅប្រាកដជាព្រេងសំណាងចូលមកសណ្ឋិតជាប្រផ្នូលនាំឲ្យត្រូវឆ្នោតហើយរុំ!

នាយខែន :– លោះអញតាយថា ក្បាលឯងមិនមែនធូនព្រោះរឿងឆ្នោតទេ !

នាយទេសៈ - រឿងអីវិញ?

នាយខែនៈ - ស្ហា! ។

## ល្បែងផ្ដាំចាស់

តាគុបនឹងយាយគុំ មានអាយុជាង ៦០ ឆ្នាំរៀងរាល់ខ្លួនហើយ ។

កូនចៅរបស់គាត់ មានផ្ទះសម្បែងបែកទៅនៅដោយខ្លួនៗអស់ទៅ, តាត់នៅស្ងាត់ជ្រងំតែពីរនាក់ប្ដីប្រពន្ធ។ ថ្ងៃមួយ, តាគាត់អផ្សុកខ្លាំង តាំងទឹកក្អកចង់លេងល្បែងអ្វីមួយគ្រាន់កែអផ្សុក ទើបចចារទៅកាន់យាយថា៖

"គុំអើយ! អញអផ្សុកណាស់ហ៊ឺ, យើងគិតចង់លេងល្បែងអីកំសាន្តចិត្តបន្តិច ហ៎!" ។

"យាយៈ - មិនដឹងជាលេងអីដូចកូនក្មេងទេ, ចាស់កកល់ចូលរណ្ដៅថ្ងៃនេះស្អែកទៅហើយនោះ ។

"តាៈ - ពីព្រោះតែចាស់ជិតចូលរណ្ដៅហ្នឹងហើយ បានជាគិតលេងផ្ដាំចាស់ឲ្យហើយទៅណា៎!

យាយៈ - អញស្អប់ណាស់! ចាស់ឡើងព្រិលឡើងៗ មើលតែស្គរដៃយុំ ។

តាៈ - កុំនិយាយលេងសើច! គ្មាននិយាយមែនខែនណា៎! យើងគិតលេងអី ហ៎! ។

យាយៈ - មានតែលេងល្បែង ១ ដែលតាឯងឡើងតាមសរសរ ហើយចូលតាមបង្អួចមកចង់ខ្ញុំកាលយើងនៅពីក្រមុំកំឡោះនោះ ។

តាៈ - អើៗ! អាហ្នឹងស្រួលហើយ! ។

យាយក៏ដើរទៅឈរចាំបង្អួចក្បាលដំណេក (ធ្វើតាមចំនងដើម) តាចុះមកដី ខំប្រឹងប្រវប្រវាឡើងសរសរគេខ្វះកខ្វាសហត់ហោបៗ- ឡើងទៅដល់ជើងជញ្ជាំងក្រោមបង្អួច តាទោរទៀតមិនរួច ទើបស្រែកហៅយាយថា" នែ! របស់យក៏ ! កាលអញឡើងមកចង់ឯងពីកំឡោះនោះ ដល់ត្រង់នេះ ក្រែងឯងហុចដៃមកឲ្យអញតោង ហើយឯងទាញយោងអញទៅតាមបង្អួចឬ? ឥឡូវមេចក៏មិនហុចដៃមក? ឆាប់ៗឡើង! អញហេវដៃណាស់ របេះធ្លាក់ឥឡូវហ្នឹងហើយ! ។

យាយៈ - ប្រញាប់អីម៉្លេះ? ព្រោះកាលណោះតាឯងឡើងដល់ត្រង់ហ្នឹង នៅប្រកែងប្រកាន់យូរបន្តិចសិនដែរ យើងលេងឲ្យដូចកាលជាន់នោះបានសប្បាយ ។

តាៈ - ទេ, អាណិតតែគ្នាទៅ! អញលែងចង់សប្បាយហើយ, ប្រញាប់ឡើងរបូតដៃធ្លាក់ឆាប់ឥឡូវហ្នឹងហើយ! យាយក៏ឱនទៅតាមបង្អួច ហុចដៃទាំងពីរទៅចាប់ដៃតាទាញយោងឡើង ។ ដោយយាយគាត់ខ្សោយកំឡាំង ហើយគេភាគឯតាគាត់ធ្ងន់ណាស់ផង ព្រោះគាត់លែងដើរពីសរសរអស់ទៅហើយៈនោះ យាយទាញអូសតាឡើង លើមិនរួចត្រឡប់ជាតាអូសយាយប្រទាញចុះក្រោមមកវិញ ស្រាប់តែរគ្រាំជល់ដីតាស្រុញគូថ, យាយស្រុញកប្រហមាត់ប្រគរលើគ្នា ព្រលឹងបោលចោលរូបទៅនៅវេលានោះឯងហោង ។

ញូង - សឿង

## ជាតិមានអ្វីជាកំឡាំង

(តពីលេខ ២ មក)



ចំពោះប្រស្នាកុមារអនាថានេះ, ប្រសិនបើរដ្ឋាភិបាល រួបរួមគ្រោងផែនដោយពេញទំហឹងជាមួយនឹងសមាគមកុមារសង្គ្រោះ យើញថាជាការប្រពៃណាស់ គឺគប្បីចាត់ចែងរកទីកន្លែងណាមួយដ៏សមគួរសង់គេហដ្ឋានមួយ ជាបណ្ដោះអាសន្នល្មមចំណុះមនុស្សបាន ១០០ នាក់ហើយប្រមូលក្មេងអនាថាទាំងនោះឲ្យនៅជុំគ្នា ទំនុកបំរុងដោយស្បៀងអាហារ និងការសំណាក់អាស្រ័យដោយគ្រប់គ្រាន់ ទំរាំសមាគមមានកំឡាំងរឹងប៉ឹងនឹងពង្រីកតទៅទៀតបាន និងសូមអំពាវនាវដល់គហបតីទាំងឡាយ ក្នុងព្រះរាជអាណាចក្រឲ្យជួយ ផ្ដល់ទប់ទល់កង្កិច្ចនេះផង-គប្បីលៃលកបង្រៀនក្មេងទាំងនោះ ឲ្យបានចេះដឹងច្បាប់អនាម័យ, អក្សរសាស្ត្រ និងសីលធម៌តាមសមគួរដល់កាលៈទេសៈដែលល្មមនឹងធ្វើទៅបាន, ឯការគ្រប់គ្រងក្មេងបែបនេះ គប្បីធ្វើដូចមាតាបិតាចិញ្ចឹមថែរក្សាបុត្រដូច្នោះឯង ។

## ការសង្គ្រោះកុមារត្រូវធ្វើដោយវិធីដូចម្ដេចខ្លះ?

ការសង្គ្រោះកុមារនេះមានច្រើនប្រភេទ; ប្រទេសខ្លះ គេផ្ដល់ប្រាក់កាសចំពោះមាតាបិតានៃកុមារក្រីក្រទាំងនោះតែម្ដង, តែនៅនានាប្រទេសនោះ បើយើងសង្កេតមើលប្រវត្តិសាស្ត្រ និងឯកសារផ្សេងៗ ដោយការពិចារណាយ៉ាងម៉ត់ចត់ទៅ ក៏ល្មមនឹងស្រង់យករឿងខ្លះមកបរិយាយក្នុងទីនេះ ដើម្បីជូនដល់អស់លោកអ្នកឲ្យបានជ្រាបតទៅ ។

ប្រទេសខ្លះគេចាត់សង់មន្ទីរសម្រាប់ឲ្យកុមារអនាថាចូលទៅសំណាក់អាស្រ័យដោយមិនចាំបាច់បង់ខាតសោហ៊ុយច្រើនក៏មាន, ឯសោហ៊ុយសម្រាប់ប្រើប្រាស់ក្នុងការចិញ្ចឹមកុមារទាំងនោះ គេតម្រូវពឹងផ្អែកទៅលើប្រជាជនអ្នកមានកុសលចិត្តឲ្យបំណាយធនធានធ្វើជាទានខ្លះៗ ក៏មានបុគ្គលខ្លះដែលប្រកបដោយករុណាចិត្តពេញលេញ គេអាចទទួលរ៉ាប់រងមុខចំណាយដោយជាប់ខាតទៅក៏មាន ។

នៅសហរដ្ឋអាមេរិក, កន្លែងសម្រាប់សង្គ្រោះកុមារច្រើន ជាភារៈលើអ្នកសាសនា, ឯសោហ៊ុយសម្រាប់ចាយវាយក្នុងមុខការនេះ ច្រើនពឹងផ្អែកទៅលើជនអ្នកមានចេតនាជាកុសលជួយឧបត្ថម្ភ ។

កាលសម័យក្រិកនិងរ៉ូម៉ាំង ដែលទើបនឹងចំរើនជាបឋមនៅប្រទេសអឺរ៉ុបនោះ, នៅក្រុងអាថែន គេបានសង់មន្ទីរមួយសម្រាប់ឧបត្ថម្ភកុមារកំព្រាអនាថា គឺកុមារណាដែលមាតាបិតាស្លាប់ចោលទាំងពីរក្តី, ដែលមាតាបិតាបោះបង់ចោលក្តី ឬដែលបិតាស្លាប់ក្នុងសង្គ្រាមក្តី, គេតែងទទួលចិញ្ចឹមជាផ្លូវការទាំងអស់, ចំណែកខាងសាសនាគ្រិស្តវិញ ក៏បានជួយរៃអង្គាសអំពីជនសប្បុរស ដើម្បីជួយទប់ទល់ក្នុងសង្គហកិច្ចនេះ, មានបួនកាលគេជួលស្រីមេម៉ាយជាច្រើនឲ្យជាអ្នកថែរក្សាកុមារទាំងនោះផង ៗ អង្គការកុមារសង្គ្រោះរបស់សាសនាគ្រិស្តនោះ លុះចំណេរតមក ក៏រេះតែបានចំរើនឡើងជាលំដាប់ដរាបដល់បង្កើតឲ្យមានមន្ទីរព្យាបាលរោគ ក្នុងវត្តផងទៀតក៏មាន ៗ

ក្នុងប្រទេសអង់គ្លេស ទីកុមារសង្គ្រោះដែលគេផ្តើមតាំងឡើងជាដំបូងបង្អស់នោះ គឺគេធ្វើជាសាលាទានសាធារណៈ ក្នុងបណ្តាជនអ្នកមានសទ្ធាចិត្ត គេឧបត្ថម្ភដល់សាលានោះ ដោយទទួលចិញ្ចឹមកុមារ, មនុស្សចាស់ៗ, មនុស្សក្រលំបាក, នៅកន្លែងខ្លះមានទទួលមនុស្សក្អែកខ្វាក់ មនុស្សវិកលចរិតផងទៀត, ៗ អំណើះតមក សាលាទាននោះ ក៏ក្លាយទៅជាមន្ទីរសម្រាប់ចិញ្ចឹមកុមារកំព្រា ដែលមិនទាន់ចេះប្រកបអាជីវកម្មដោយផ្ទាល់ខ្លួន ៗ

ក្នុងសម័យជាក្រោយមក ខាងគ្រិស្តសាសនាបានបង្កើតមន្ទីរសង្គ្រោះកុមារ ដោយមានការឧបត្ថម្ភអំពីជនអ្នកមានសទ្ធាទាំងឡាយ, ចំណែកខាងឯការសិក្សានោះវិញសោត ផ្នែកខាងសាលាទានគេបានសង់សិក្ខាគារឡើង ដើម្បីការសិក្សារបស់កុមារកំព្រាដែលនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ៗ ចំណែកខាងរដ្ឋាភិបាលក៏ជួយ ដោយតាំងសាលារៀនពិសេសផ្សេងដោយឡែក ៗ ក្នុងសិក្ខាគារកុមារកំព្រាទាំងនោះ កុមារទាំងឡាយតែងបានទទួលការសិក្សា ទីអាស្រ័យនឹងស្បៀងអាហារដោយគ្រប់គ្រាន់ ម៉្លោះហើយក្នុងទីខ្លះមានដល់ទៅជាងពាន់នាក់ក៏មាន ដោយការអ៊ូអររបស់កុមារក្នុងសង្គមយ៉ាងនេះតមក ទីនោះក៏ក្លាយទៅតាមសាមញ្ញភាសាថាបន្ទាយទាហាន ព្រោះមានការហ្វឹកហាត់ទៅតាមវិភាពទាហានផង ៗ សិក្ខាគារណាដែលមានសភាពជាប់គ្នា គេច្រើននិយមហៅថា "ភូមិ" ព្រោះមានលក្ខណៈដូចជា ភូមិ ៗ

ក្នុង ព. ស. ២៤៣៦ អង់គ្លេសបានចាត់តាំងកន្លែងថ្មីមួយផ្សេងទៀត សម្រាប់ចិញ្ចឹមកុមារអនាថា ជាជំនួសកន្លែងដែលតាំងនៅជាប់ ៗ គ្នានោះ ឲ្យវែកឃ្លាតពីគ្នាចំនួនមួយវិថី ហើយមានមេត្រួតសម្រាប់ថែទាំមើលការខុសត្រូវសុខ-ទុក្ខគ្រប់យ៉ាង; កុមារទាំងនោះក៏មានឱកាសចូលទៅរៀនតាមសាលារៀនរដ្ឋ-ការ ដែលនៅជិតៗ បានដូចគ្នានឹងក្មេងដទៃដែរ ៗ

កាលពុទ្ធសករាជ ២៤៦៩ ក្នុងប្រទេសអង់គ្លេស មានកុមារអនាថាប្រហែល ៦៩.០០០នាក់ កុមារជាង ១០.០០០ នាក់ ទៅនៅក្នុងគ្រួសារដទៃ, ១៨.០០០ នាក់ នៅក្នុងសាលាទាន, ៣២.០០០ នាក់ នៅក្នុងសាលារៀន ដែលរដ្ឋាភិបាលតាំងឡើងសម្រាប់ប្រទេស សល់អំពីនោះក៏បែកខ្ញែកគ្នាទៅនៅតាមទីអប់រំផ្សេងៗ ទៀត; ក្នុងពុទ្ធសករាជ ២៤៧១ កូនអនាថា ក៏បានថយចំនួនចុះជាច្រើន រឿងនេះមកអំពីរដ្ឋាភិបាលមានប្រាក់ អាចជួយសង្គ្រោះដល់ស្រីមេម៉ាយ, កុមារកំព្រា, និងមនុស្សជរាថែមទៀត កាន់តែច្រើនឡើង ៗ

ក្នុងប្រទេសអាមេរិក គេបានបង្កើតសមាគមមួយហៅថាសមាគមកុមារសង្គ្រោះ កើតឡើងដោយស្នាដៃលោកអ្នកសប្បុរសម្នាក់ឈ្មោះ "ឆាលឡរីង-ប្រេស" លោកនេះបានតាំងខ្លួនជាសមាគមុបត្ថម្ភមុនគេបង្អស់ ក្នុង ព.ស. ២៣៩៦ ។ មានទីសំណាក់ការនៅក្រុងនីវយ៉ក, វត្ថុបំណងរបស់សមាគមនេះ ចំពោះតែការសង្គ្រោះកុមារដែលក្រីក្រលំបាក ឥតទីពឹងដែលនៅក្នុងក្រុងនីវយ៉កប៉ុណ្ណោះ នៅពេលដែលលោក ឆាលឡរីងប្រេស បានតាំងសមាគមនេះសម្រេចពេលណា, អ្នកឯទៀតដែលមានមនោសញ្ចេតនាស្រប នឹងលោកដែរក៏តាំង នាំគ្នាបង្កើតសមាគមកុមារសង្គ្រោះពេញទូទៅទាំងប្រទេសអាមេរិកក្នុងរយៈពេលមិនយូរប៉ុន្មាន, ឯសមាគមរបស់លោកឆាលឡរីងប្រេស ក៏ចាប់ផ្ដើមសង់សិក្ខាគារឧស្សាហកម្មកុមារីឡើងជាដំបូង ហើយចាត់តាំងសាលាទានលៀងភោជនដល់ពួកកុមារក្នុងពេលថ្ងៃ សង់ផ្ទះសំណាក់សម្រាប់កុមារដែលលក់កាសែត ប្រមូលកុមារដែលគ្មានទីសំណាក់អាស្រ័យ ឲ្យបានទៅនៅតាមគ្រួសារផ្សេងៗ ។

ក្នុងពុទ្ធសករាជ ២៣៩៨ សមាគមចាត់តាំងធនាគារសម្រាប់ទទួលប្រាក់បញ្ញើ បន្តិចបន្តួចដែលកុមារអនាថាទាំងនោះរកបានមក, តពីពេលនោះ ៤ ឆ្នាំចាត់តាំងបណ្ណាល័យជាសាធារណៈ សម្រាប់ឲ្យកុមារទៅអង្គុយមើលសៀវភៅក្បួនខ្នាតផ្សេងៗ បាន ។

ក្នុងពុទ្ធសករាជ ២៤០៦ គេបានចាត់តាំងផ្ទះសម្រាប់កុមារីសំណាក់នឹងទីប្រជុំរបស់មាតា ។

ក្នុងពុទ្ធសករាជ ២៤១៤ បានបង្កើតកន្លែងមួយសម្រាប់ឲ្យកុមារអនាថាទាំងឡាយ មានឱកាសទៅជួបមុខគ្នា កន្លែងនោះគេចាត់ទុកជាកន្លែងកណ្ដាល, ៤ ឆ្នាំទៀត គេបានចាត់តាំងមន្ទីរព្យាបាលរោគមួយឡើងឲ្យឈ្មោះថាអគ្គការអប់រំសុខភាព ដោយរួមគំនិតនឹងកាសែត" នីវយ៉កថែម" ក្រោយមកទៀតមួយឆ្នាំ គេបានចាត់តាំងគេហស្ថានសម្រាប់ក្នុងរដូវក្ដៅសម្រាប់កុមារអនាថាថែមទៀត, ក្នុងពុទ្ធសករាជ ២៤១៩ បង្កើតសិក្ខាគារអនុបាលទារក សម្រាប់កុមារអនាថា ដោយគ្មានបង់ខាតសោហ៊ុយក្នុងការសិក្សា ហើយបានតាំងបណ្ណាល័យ សម្រាប់សាលារៀនមួយ

បន្ទប់, មន្ទីរព្យាបាលរោគនៅមាត់ទន្លេសម្រាប់មាតានិងទារកឣនាថាជាដំបូង, បានសាងឡើងកោះនៅខននី កាលពីពុទ្ធរាជ២៤២៧, តំណអំពីនោះមក៣ឆ្នាំគេបានតាំងកន្លែងមួយសម្រាប់កុមារពិការក្បែរមាត់ទន្លេក្រុងបាកជាទីដែលមានអាកាសល្អ ឯកន្លែងកីឡាសម្រាប់កុមារលេង គេបានចាត់តាំងឡើងតាមសាលារៀននានា ពីពុទ្ធសករាជ២៤៣៧ ចំពោះសាលារៀនសម្រាប់ក្មេងពិការគេបានសាងឡើង ពីពុទ្ធសករាជ២៤៤១ ។

នៅក្នុងសហរដ្ឋអាមេរិក គេបានចាត់តាំងសមាគមសង្គ្រោះកុមារឣនាថាជាលំដាប់ៗមក រាប់បានចំនួនជាងរយឡើងទៅ នៅគ្រប់តែសមាគម គេតែងមានសេចក្ដីប្រឹងប្រែងគិតរកឧបាយដែលគួរឧប-ត្ថម្ភដល់កុមារឣនាថា ឲ្យបានទទួលការព្យាបាលរឹងរឹតតែស្រួលឡើងជាលំដាប់ ដើម្បីឲ្យបានសមរម្យក្នុងពេលដែលគ្នាបានកើតមកជាមនុស្សនឹងគេហើយនោះ ។ ការដែលចាត់តាំងកន្លែងនឹងរបៀបសង្គ្រោះកុមារឣនាថានោះតាមសមាគមនានា សឹងមានសមាសភាពស្រដៀងៗគ្នាទាំងអស់ ។

កាលពុទ្ធសករាជ២៤៩២ ប្រធានាធិបតីពេសវេល្ដ បានថ្លែងក្នុងទីប្រជុំគណៈរដ្ឋមន្ត្រី អំពីរឿងសង្គ្រោះកុមារឣនាថាជាការដែលធ្វើឲ្យកុមារឣនាថាទាំងឡាយមានចិត្តប្រើមជាប្រក្រតី បានទទួលការអប់រំនឹងការចិញ្ចឹមបីបាច់ថែរក្សាយ៉ាងគ្រប់គ្រាន់ ដូចជានៅក្នុងគ្រួសាររបស់ខ្លួន របៀបដែលល្អគួរតែបញ្ចូនក្មេងទាំងនេះ ឲ្យទៅនៅក្នុងមន្ទីរដែលបានជ្រើសរើសដោយត្រឹមត្រូវ ដែលអាចនឹងគ្រប់គ្រងកុមារឣនាថាបានប្រហែលគ្នានឹងមាតារក្សាបុត្ររបស់ខ្លួន ។

មហា ឆាង (នៅមានត)

# ខែខាងសុរិយគតិ

ដើម្បីនឹងឲ្យយល់ខែខាងសុរិយគតិដោយងាយត្រូវយល់ ពាក្យថា **Signe de zodiaque** នោះសិន; **Signe de zodiaque** គឺជារង្វង់មូលនឹងមានរង្វង់មូលមួយទៀត ដែលព្រះអាទិត្យធ្វើដំណើរជុំវិញដីក្នុងមួយឆ្នាំ ៗ រង្វង់មូលមួយទៀតនេះ, ភាសាបារាំងហៅថា **écliptique** ស្ថិតនៅចំកណ្ដាលហើយមានភាគ១២ ៗ រឿងហ្នឹងនេះមានខាងវិទ្យាតារា-សាស្ត្រ, ឣ្នកណាដែលមិនបានរៀនវិទ្យានេះមិនអាចយល់បានទេ, ព្រោះភាគទាំង១២នេះ មានរូបផ្សេង ៗ ពីគ្នា, តែដែលបណ្ឌិតខាងតារាសាស្ត្របានធ្វើភាគទាំងនោះ មានរូបផ្សេង ៗ តើដោយហេតុអ្វី? ខ្ញុំមិនអាចដឹងដល់ ឯភាគទាំង១២នោះគឺ:

| | |
|---|---|
| ១ – មករៈ | ២ – កុម្ភៈ |
| ៣ – មីនា | ៤ – មេសា |
| ៥ – ឧសភា | ៦ – មិថុនា |
| ៧ – កក្កដា | ៨ – សីហា |

៩ – កញ្ញា　　១០ – តុលា

១១ – វិច្ឆិកា　　១២ – ធ្នូ

បើពិចារណាតាមរដូវគឺ:

១ – និទាឃរដូវ (**Printemps**) គឺខែមេសា, ឧសភានិងមិថុនា (ថ្ងៃទី ២១ មីនាទៅដល់ថ្ងៃទី ២១ មិថុនា) ។

២ – វស្សានរដូវ (**Eté**) គឺខែកក្កដា សីហានិងកញ្ញា (ថ្ងៃទី ២២ មិថុនា ទៅដល់ថ្ងៃទី ២២ កញ្ញា) ។

៣ – សរទរដូវ (**Automne**) គឺខែតុលា, វិច្ឆិកានិងធ្នូ (ថ្ងៃទី ២៣ កញ្ញាដល់ថ្ងៃទី ២១ ធនុ (ធ្នូ) ។

៤ – សិសិររដូវ (**Hiver**) គឺខែមករា, កុម្ភៈ, និងមីនា (ថ្ងៃទី ២២ ធ្នូទៅដល់ថ្ងៃទី ២០ មីនា) ។

យើងមិនអាចដឹងបានថាភាគទាំង ១២ នេះ ហេតុម្តេចក៏ត្រូវយកមក ហៅជាខែតាមសុរិយគតិទៅវិញ? ។ ប្រហែលជាភាគទាំង ១២ នេះស្ថិតនៅក្នុងវង់ដំណើរនៃព្រះអាទិត្យដែលវិលជុំវិញព្រះធរណីក្នុងរយៈវេលាមួយឆ្នាំ, គឺ ១២ ខែៗ នេះជាភាគ ១២ នេះឯង ។ តែគួរឆ្ងល់ថាព្រះចន្ទវិលជុំវិញព្រះធរណីក្នុងរយៈវេលាមួយឆ្នាំម្តេចក៏មាន ១២ ខែ គឺ ១២ ផ្កាយឬភាគនោះដែរ: មាឃ, ផល្គុន, ចេត្រ, វិសាខ, ជេស្ឋ, អាសាឍ, ស្រាពណ៍, ភទ្របទ, អស្សុជ, កត្តិក? ។ ខែទាំង ១២ គឺភាគ ១២ ដែលជាខែខាងចន្ទគតិ ។ សុរិយគតិនិងចន្ទគតិ រួបរួមទៅជាវិទ្យាខាងភាគសាស្ត្រនិង ហោរាសាស្ត្រជាវិទ្យាពីរដោយខ្សែក ដែលមានអត្ថន័យសុខុមគម្ពីរភាពមានការពិចារណាភាគ ព្រះអាទិត្យ, ព្រះចន្ទ, ព្រះធរណី, លក្ខណៈ, ចម្ងន់, កំណើត, ព័ណ៌, រស្មី, ល្បឿននៃរស្មី, ការគមនាគមន៍ភាគនិងជោគវាសនារបស់មនុស្សនិងជីវិតពិភពលោកចក្រវាឡ, លោកធាតុជាដើម ។

នៅទីនេះ សូមពណ៌នាដោយសង្ខេបអំពីខែខាងសុរិយគតិ គឺ:

១-មករា វចនានុក្រមខ្មែរ ថាមក ពីភាសាសំស្ក្រឹត "មករ" ប្រែថា "ត្រីសមុទ្រមួយយ៉ាងមានខ្លួនធំ ក្បាលទ្វីក្រមុំបញ្ចេញនិងចង្កូមស្នាញគួរស្ញើម (មានដំណាលក្នុងរឿងរ៉ាវតាំងពីព្រេងនាយ) ខ្មែរហៅលំនៅត្រី ឬក៏មាន, ច្រើននិយាយថាត្រាមមករ ។ មករនេះទៅជាមករាសីគឺឈ្មោះខែទី ១០ នៃសុរិយគតិ, មាន ថ្ងៃ ៣០, ត្រូវគ្នានឹងខែយ៉ាំងវីយេរ (ខែទី ១) បារាំង-សែស ។ដើម្បីនឹងស្រួលពោល, បណ្ឌិតបានហៅខែនេះថា "មករា" ។

តែបើតាមវចនានុក្រមបារាំង "ឡារុស្ស" និងរូបគំនូរ វង់មូលដែលគេហៅថា "**Signe de zodiaque**" ខែមករានេះ ត្រូវនឹងភាគមួយ ពាក្យបារាំងហៅថា "**Capricorne**" ពាក្យនេះ មកពីភាសាឡាតាំង ថា "**Capro**" ប្រែថាពពែញី ហើយភាគនេះមានស្ថានរូបលក្ខណៈដូចជារូបពពែញីទៅវិញ ។ ព្រះអាទិត្យធ្វើដំណើរជុំវិញព្រះធរណីមកដល់ភាគនេះចូលទៅក្នុង

ដែលស្មានមូលហៅតាមភាសាបារាំងថា " Tropique du Capricorne" គឺជាវង្វង់មូលមួយ នៃចក្រវាឡ មានគំនូសបណ្ដោយ និង គំនូសកណ្ដាលដែលហៅគំនូស ជាគំណើរព្រះអាទិត្យ, ពាក្យបារាំងថា "Équateur" ។ គំនូស "Torpique de Capricorne "ស្ថិតនៅខាងត្បូងគំនូស "Équateur" ។ នៅប្រឡោះគំនូសទាំងពីរនេះបញ្ជាក់ឲ្យឃើញដំណើរព្រះអាទិត្យក្នុងរយៈវេលាប្រាំមួយខែ គឺពីខែមករាទៅដល់ខែ មិថុនា ត្រូវនឹងរដូវពីរគឺសិសិររដូវ (រដូវរងា) (Hiver) និងនិទាឃរដូវ(រដូវស្លឹកឈើលាស់) ( Printemps) ។ តែខ្ញុំមានសេចក្ដីសង្ស័យពន់ពេកថា Capricorne ដែលមានរូបជាពពែញីម្ដេចក៏ទៅត្រូវនឹងខែមករា ដែលយើងប្រែថា ត្រីមករទៅវិញ? មានខ្លះឆ្លើយថា ប្រហែលជាពពែញី កើតពីត្រីមករ ។ ត្រង់នេះស្រេចនៅបណ្ឌិតចំណានវិនិច្ឆ័យគ្នាចុះ? ។ បើជាក់ខែនេះ ជា អជា ប្រែថា "ពពែញី" ប្រហែលត្រូវគ្នានឹងភាព "Capricorne" ។ ចំណែកបណ្ឌិតខាងប្រទេសថៃឡង់គេហៅខែនេះថា មករាគមកដែរ, តែមិនដឹងដោយហេតុអ្វី ?

តែបើតាមជាងវិចិត្រករម្នាក់នាម ប៉ុលដឺលិមបួរ បានគូររូបមនុស្សនៅសារមន្ទីរ ក្នុងដេ(ទីក្រុងសង់ទីយេ ថា: Capricorne ជាសត្វមួយកំណាត់ពពែញីមួយកំណាត់ទៀតត្រីសមុទ្រ បារាំងហៅថា Dauphin , ប្រហែលជាត្រីម្ករទេដឹង ?

២- កុម្ភៈ ភាសាបាលីប្រែថា ក្អម គឺខែខាងសុរិយគតិជាកុម្ភរាសី គឺឈ្មោះ ខែទី១១មានថ្ងៃ២៨ឬ ២៩ត្រូវគ្នានឹងខែហ្វេវ្រីយេរ ខាងបារាំង ។

បើតាមវចនានុក្រមបារាំង "ឡារុស្ស ", ភាសាបារាំងថា "Verseau" មានរូបមនុស្សកាន់ក្អមទឹកលើកឡើង

កាយ-ប៊ុត

(នៅមានត)

---

# រឿងជ័យប្រាជ្ញ

## ភាគទី ៤

មានថ្ងៃមួយ ជាថ្ងៃជិតចូលដល់ថ្ងៃបុណ្យ ចំរើនព្រះជន្មវស្សាថ្វាយព្រះមហាក្សត្រ ។

កុមារជ័យបានចូលទៅក្រាបបង្គំគាល់ ព្រះមហាក្សត្រ សូមព្រះរាជានុញ្ញាត នឹងធ្វើជាពេធល្បាំមួយឲ្យឈ្មោះថា "ល្បាំល្បែងក្មេង" ដើម្បីនឹងបាតការលេងថ្វាយចំពោះព្រះរាជករុណាធិគុណ ជាព្រះកិត្តិយស ក្នុងឱកាសនៃពិធីបុណ្យចំរើនព្រះជន្មវស្សានោះ ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ហើយមានព្រះដម្រាស់ថា "អាជ័យនេះជាក្មេងមានប្រាជ្ញា លើសអស់ក្មេងទាំងឡាយដទៃ បើអញបើកឱកាស ឲ្យវាបាតការបើកល្បែងនោះលេងទៅប្រហែលជាវាអាចនឹងរៀបចំបានដូចជាសំដីរបស់វាមែន" ក្រោយដែលទ្រង់មានព្រះដម្រាស់ដូច្នោះ ព្រះអង្គទ្រង់ព្រះរាជទាន រង្វាន់ជា

ប្រាក់ ៣០០ កហាបណៈ ដល់កុមារជ័យ ដើម្បីចាត់ចែងទៅតាមបែបនៃពិធីល្បិចនោះ ៗ កុមារជ័យ លុះទទួលព្រះរាជអំណោយហើយ ក៏ក្រាបបង្គំលាព្រះមហាក្សត្រថយមកលំនៅអាត្មាវិញ ៗ របៀបដែល

ទីងត្រូវចាត់ចែងកេងពិធីជ័យកុមារបានជួលមនុស្សឲ្យជីកដីជម្រៅ៦ហត្ថទទឹង ៤ ហត្ថបណ្ដោយ ៦០ ហត្ថ បត់ជាកែងត្រង់ទៅម្ខាង គឺក្នុងមួយល្បត់ ៣០ ហត្ថ យកក្ដារមកសន្ធប់ឲ្យជិតពីលើទាំងអស់ទុកតែ ២កន្លែង គឺកន្លែង១ជាផ្លូវចូលមួយទៀតជាផ្លូវចេញ ៗ ទំហំមាត់ច្រកចូល ៤ ហត្ថមានជញ្ជាំង អមមាត់ច្រកចូលទៅខាយចំនួន ១០ហត្ថទើបខណ្ឌក្ដិត ៗ នៅត្រង់ពាក់កណ្ដាល ចម្ងាយជា៤ ហត្ថពីជញ្ជាំងនោះមក ដាក់បន្ទះក្ដារមួយ ដែលមានគន្លឹះសម្រាប់ឲ្យអ្នកដើរចូលទៅជាន់បាស់ធ្លាក់ទៅក្នុងរណ្ដៅ ថយពីមាត់ទ្វារចូលបន្តិចមក មានរោក់ឡប់ខ្សែ១ ប៉ាំងកុំឲ្យគេមើលឃើញ ៗ នៅត្រង់មាត់ច្រកចេញ ធ្វើជាបន្ទប់មួយបាំងក្ដារភ្ជាប់ពីជញ្ជាំងមាត់ទ្វារ លយចូលមកក្នុងបន្តិចមានបន្ទះក្ដារគ្រាល បើកបិទបាន ហើយដាក់ជណ្ដើរចុះទៅក្រោមសម្រាប់ឲ្យអ្នកឡើងពីក្រោមមក បើកក្ដារចេញទៅក្រៅ ថយពីមាត់ទ្វារចេញនោះបន្តិចមកខាងក្នុង ដាក់ឡប់ខ្សែ១ ប៉ាំងដូចជាមាត់ទ្វារចូលដែរ ៗ

ថៃ-ជុង

(នៅមានត)



## បៅស្មែងទន្សាយធ្វើដំណើរព័ទ្ធពិភពលោក

តពីលេខ ២ មក

លុះបាយរួចហើយ, លោកតាព្រិនបាលក៏ចាប់ផ្ដើមនិទានរឿងប្រទេសណឺប៉ាល់តទៅទៀតថា : ការដែលរចនាប្រទេសនេះ ឲ្យមានដំណើរទៅតាមសម័យនិយមធ្វើឲ្យប្រជាជាតិ(១)យល់ទៅតាមសភាពផ្សេងពីសម័យមុនច្រើន ៗ ពីដើមជនជាតិណឺ-ប៉ាល់យល់ថា ប្រទេសណឺប៉ាល់បង្កើតឡើងដោយព្រះមហាក្សត្រ ទីងព្រះរាជវង្សរាណៈដែលទ្រង់ប្រមូលនូវព្រះរាជទ្រព្យជាច្រើនហើយទីងកងទ័ព កសាងព្រះបរមរាជវាំងមួយ ដែលត្រូវគ្រាន់ទៅដោយសេនា-មាត្យ ជាព្រះរាជបរិពារនៅទីក្រោះក្ដុកត័មង់ឌូ ៗ អ្នកដំណើរដែលចាកចេញពីខេត្តផ្សេង ៗ បើកាលណាមកដល់ក្ដួប ៗ ដែលជាព្រំដែន; អ្នកដំណើរនេះត្រេកអរទៅឃើញចម្ការទីងទីពិសិដ្ឋ(២) នៃក្រោះក្ដុកត័មង់ឌូ(៣) ហើយក៏លើកដៃអញ្ជលីគម្ពស្រែកថា :

(១) មតិប្រជារាស្ត្រ៖ បេះបេល, គំនិតប្រជារាស្ត្រ ។

(២) តីទីដែលគេគោរពបូជា, ហៅថា បូជនិយដ្ឋានក៏បាន ។

(៣) កង្ហមេណ្ឌា (មណ្ឌបធ្វើពីឈើ)

"ណីប៉ាល! ណីប៉ាល!" ។

ឥឡូវក្នុងភាគនីមួយៗ នៃប្រទេសនេះ មានការចម្រើនខាងឧស្សាហកម្មនិងកសិកម្ម ព្រមទាំងទីគមនាគមន៍ ។ ក្នុងប៉ុន្មានថ្ងៃមុននេះ មានកុនមកលេងជិតវត្តក័តមង់ឌូ! ក្មេងមហោស្រពនៃកុននោះ បានបញ្ចេញសំឡេងពីសព្ទយន្ត[១] និងវិទ្យុផ្សាយដំណឹងទៅតាមវិថីក្នុងទីក្រុង ។ មានកាមោដ្ឋាន[២] មួយដែលគេរៀបចំឡើងដោយ តុ កៅអី និងតុរូបត្រូវយ៉ាងពិសេស បានស្ថាបនានៅក្នុងព្រះបរមរាជវាំងនៃសន្តតិវង្សរាណះ ។

នេះជាសេចក្ដីពណ៌នាដោយសង្ខេបអំពីស្ថានភាពបច្ចុប្បន្ននៃប្រទេសនេប៉ាល ។

ចៅ "ស្នេងទន្សាយ" ក៏បានសួរទៅលោកតាព្រឹទ្ធបាលទៀតថា: "ខ្ញុំចង់ស្ដាប់ប្រវត្តិសាស្ត្រនៃប្រទេសនេប៉ាលដោយសង្ខេប, សូមលោកតាមេត្តាពណ៌នាឲ្យខ្ញុំស្ដាប់ផង ។ ខ្ញុំសូមអរគុណលោកតាជាមុន" ។

ប្រវត្តិសាស្ត្រនៃប្រទេសនេប៉ាល គេទើបនឹងស្រាវជ្រាវរកឃើញត្រឹមសតវត្ស ១៦ នៃសន្តតិវង្សអយុធ្យា ដល់មកសតវត្ស ១៣ មានផ្លាស់សន្តតិវង្សថ្មីហៅថាសន្តតិវង្សមល្ល: ។

ហ៊យ-ប៊ុត

(នៅមានត)

(១) សព្ទយន្តគឺម៉ាស៊ីនច្រៀង (២) កាមោដ្ឋានៈ ផ្ទះសម្រាប់លេងល្បែងកំសាន្តសប្បាយ, ផ្ទះដែលមានកាមារម្មណ៍ រូប, សំឡេង, ក្លិន, រស, សម្ផស្ស ។

# បញ្ចតន្ត្រៈ

តពីលេខ ២ មក

លុះបានស្ដាប់ហើយ ចៃមន្ទីរសបិណ៌និយាយថា: "ឱសេដ្ឋីអើយ យើងជញ្ជក់ព្រះលោហិតនៃព្រះរាជានេះ តែកាលណាព្រះរាជាទ្រង់ផ្ទំលក់ស្កប់ បើឯងចង់ទៅជញ្ជក់ព្រះលោហិតនេះដែរ ទៅចុះជញ្ជក់ព្រះលោហិតតាមគាប់ចិត្តឯង តែត្រូវបរិភោគក្រោយខ្ញុំ ។ សង្កើចអគ្គិមុខឆ្លើយតបថា: "ខ្ញុំមានចិត្តត្រេកអរណាស់ ខ្ញុំនឹងធ្វើយ៉ាងនេះតទៅ, បើលោកមិនទាន់បានជញ្ជក់ព្រះលោហិតមុនទេ ហើយខ្ញុំទៅបរិភោគមុនសូមឲ្យសម្បថនៃព្រះព្រហស្បតិធ្លាក់លើខ្ញុំចុះ" ។ ក្នុងពេលសត្វទាំងពីរនិយាយគ្នាដូច្នេះ ព្រះរាជាទ្រង់ស្ដេចចូលកាន់ព្រះទែនសយនាគ្រឡាបន្ទំ ។ កាលនោះ សង្កើចមានក្ដីស្រេកឃ្លានដោយល្មោភខ្លាំង ក៏ចោះព្រះកាយដោយចុងចំពុះស្រួចដូចម្ជុល ក្នុងពេលដែលទ្រង់មិនទាន់ផ្ទំលក់ស៊ប់, ព្រោះថា: –

២៥៧– សភាពនៃទុរជន (យ៉ាងណានៅយ៉ាងនោះ) បុគ្គលមិនអាចធ្វើឲ្យប្រែកាយទៅផ្សេងៗ ដោយឧបទេសណាមួយបានដោយងាយទេ ដូចទឹក បើទុកជាក្ដៅពុះក្រិក ៗ ក៏នឹងទៅជាត្រជាក់តាមប្រក្រតីដើមវិញ

ព្រះមហា ថ៉ាង-ខាន់

(នៅមានត)



# ប្រវត្តិនៃក្មេងកំព្រា

តពីលេខ ២ មក

កិត្តិសព្ទល្បី ខាងការអប់រំពុទ្ធសាសនាក្នុងទីរួមខែត្រ កំពត ។ នៅថ្ងៃ ១៥ កើត ខែមាឃ ប្រជាជនក្នុងភូមិ បានផ្តើមធ្វើពិធីមួយហៅថាពិធីមាឃបូជា រំលឹកដល់ថ្ងៃ មហាសន្និបាតដែលព្រះអរិយសង្ឃទាំងឡាយមកជួបជុំ ក្រោមអធិបតីភាពនៃព្រះបរមគ្រូដោយគ្មានណាត់ពេល ទុកជាមុន; ជនជាពុទ្ធបរិសទ្យទាំងឡាយនិមន្តន៍លោក គ្រូចៅអធិការវត្តព្រៃតុម្តមក ប្រទានធម៌ទេសនាក្នុងរាត្រី ១៥ កើត ខែមាឃនោះ ។ លោកគ្រូចៅអធិការលោកនិមន្តតាមផ្លូវរុក្ខារក្ស ដូចបានរៀបរាប់ពីខាងដើមមក ។ តាមផ្លូវ ដែលលោកនិមន្ត, សូរសព្ទនៃគ្រឿងគោពាហនៈ ទាំងឡាយលាន់រំពងពេញទាំងព្រៃ វិស័យ ដូចជាទីប្រជុំនៃនាយគោបាល; បន្តិចមក ដំណើររបស់លោក ក៏ត្រូវចុះកាត់តាមភូមិចាស់ នៃក្មេងទុកសំណាង ។

ពេលដែលលោកនិមន្តដល់ទីដីភូមិចាស់នេះ សេចក្តីសង្ស័យក្នុងព្រះទ័យរបស់លោក ក៏កើតឡើង ដោយឃើញហ្វូងពាហនៈជាច្រើន ហើយនៅចំ កណ្តាលមានឃើញកុមារម្នាក់ មានសំលៀកបំពាក់ រយ៉ីអង្គុយបោចស្មៅ នៅជុំវិញផ្នូរខ្មោចមួយ នៅ លើផ្នូរនោះ ឃើញមានផ្កាឈើព្រៃដោតពាសពេញ; លោកអត់ទ្រាំពុំបាន និមន្តចូលទៅជិតកុមារកំសត់ នោះមានពុទ្ធដីកាសួរថា នែ! អានាង! ចុះហេតុ ម្តេចបានជាឯងមកអង្គុយដកស្មៅនៅក្បែរផ្នូរនេះ ? អ្នកណាជាអ្នកកាច់ផ្កាឈើមកដោតលើផ្នូរនេះដែរ ? កុមារសំណាង ងើបក្បាលឡើងមានទឹកមុខក្រហម ដូចជាផ្កា តែបើតាមពិនិត្យទៅគេឃើញក្មេងនោះ មានភ្នែករលីងរលោង ហើយក៏តបពុទ្ធដីកាព្រះ មហាថេរតាមការដែលមានមកហើយ ។

ព្រះមហាថេរកាលបើបានជ្រាបហេតុនោះ ករុណា



ញូត-ហៀម

នៅមានត

# មិត្តនៅខែត្រ

ខ្ញុំតែងទន្ទឹងចាំរឿងរបស់មិត្រ ដើម្បីចុះក្នុងទស្សនាវដ្ដីយើង; សូមមិត្រសំដែងសេចក្ដីអង់អាចនឹងស្វាម័គ្គិ ចំពោះសាសនានឹងមហាក្សត្ររបស់យើង វេលាដែលប្រទេសកំពុងតាំងនៅក្នុងភយន្តរាយ ។ ចូរមិត្តចាំថា ទស្សនាវដ្ដីនេះមិនមានហាមឃាត់សិទ្ធិនឹងជនណាមួយឡើយ; យើងនឹងទទួលអត្ថបទរបស់មិត្តដោយរីករាយ ។

ដូចជាពុំទាន់ឃើញយោបល់របស់មិត្រ ចំពោះអត្ថបទដែលយើងបានចុះផ្សាយនោះ ពុំដឹងជាមិត្តគាប់ចិត្ត ឬពុំគាប់ចិត្ត ។

## ឆ្លើយបំណោទ្យ ទី ១

ទីជួបគ្នា នៅសមាគមមិត្តសាលាបាលី ។

### សេចក្ដីពន្យល់

នគរវត្តជាបូរាណវត្ថុ ដែលបុព្វបុរសខ្មែរកសាងឧទ្ទិសចំពោះព្រះពុទ្ធសាសនា; ក្នុងពេលជារាជធានីនៃព្រះមហាក្សត្រសម័យបច្ចុប្បន្ន ព្រះអង្គជាអគ្គសាសនូបត្ថម្ភ ក៏ទ្រង់មានព្រះរាជនយោបាយឲ្យប្រទេសមានវិវត្តន៍ទៅតាមព្រះពុទ្ធសាសនា ។

សមាគមយើងជាអ្នកដើរតាមព្រះរាជនយោបាយ បើអស់លោកស្របបំណងយើងខ្ញុំ ពិតជាបានជួបគ្នាក្នុងឋានៈជាមិត្តនៃសមាគម ។

### ព្រះពុទ្ធសាសនាប្រទេសកម្ពុជាទទួលទុក្ខព្រួយ

មានការបៀតបៀនដោយហេតុពីរយ៉ាង គឺ:

១ – ការបៀតបៀនមិនចេញមុខ,

២ – ការបៀតបៀនដោយបង្ខំ,

យើងសូមសួរចំពោះអ្នកទាំងនោះថា សាសនាព្រះពុទ្ធជាម្ចាស់មានសត្រូវអ្វីនឹងអស់អ្នកដែរឬ? ហេតុម្ដេចក៏អ្នកក្ដៅក្រហាយនឹងព្រះពុទ្ធសាសនាម៉្លេះ? ព្រះពុទ្ធសាសនាមានបង្កសង្គ្រាមនឹងអ្នកពីកាលណា? ព្រះពុទ្ធសាសនាតែងតែរក្សាសេចក្ដីស្ងប់រៀបរយតែម្យ៉ាង ។

អ្នកទទួលឲ្យជាវ

សូមផ្ញើចំពោះទៅលោកម៉ៅ-មី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ ។

**adresse :** *Monsieur* **Mao-Mey** *Ministère de l'intérieur P. Penh*

សូមអស់លោក អភ័យ សាសនាប្រទេសជប៉ុន គណៈកម្មការកែប្រែពុំទាន់ ។